ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម

# នៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល

**ដោយ**/By

**សឿន សុខណាង**/Mr. SOEUN SOK NANG

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា២០១៨ - ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្ដម នៅវិទ្យាល័យនានាក្នុងខេត្តកណ្ដាល

**ដោយ/By**

**សឿន សុខណាង**/Mr. SOEUN SOK NANG

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០១៨ - ២០២០

**គ្រូដឹកនាំបង្គោលៈ** ឯកឧត្ដម ងៀ សុផន

**គ្រូដឹកនាំរងៈ** លោកបណ្ឌិត ឈាង សទ្ធាត

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា ***"តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល"*** សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារណាមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬពុំបានចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ គឺពិតជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃ សៅរ៍ ៨ កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២០

**ហត្ថលេខាបេក្ខជន**

**សឿន សុខណាង**

# លិខិតបញ្ជាក់

**ឯកឧត្តម ឆៀ សុផន** ជាគ្រូដឹកនាំបង្គោល

**លោកបណ្ឌិត ឈាង សទ្ធាត** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **សឿន សុខណាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ **"តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម នៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល"** ប្រាកដមែន។

ថ្ងៃ សៅរ៍ ៨ កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២០

............................................................ ......................................................................

| | |
|---|---|
| **ឯកឧត្តម ឆៀ សុផន** | **លោកបណ្ឌិត ឈាង សទ្ធាត** |
| ប្រធាននាយកដ្ឋានបុគ្គលិក | គ្រូឧទ្ទេស |
| ក្រសួងអប់រំ យុវជន និងកីឡា | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៥៣០៧ **អយក.ខគ**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វិសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២

អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់ក្រសួងអប់រំ យុវជន និងកីឡា និង វិទ្យាស្ថានជាតិអប់រំ ដែលបានផ្តល់អាហារូបករណ៍ដល់រូបខ្ញុំបាទរហូតបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណារ៉ា** នាយកវិទ្យាស្ថានជាតិអប់រំ ព្រមទាំង លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីផ្ទេរចំណេះដឹង បំណិន ឥរិយាបថ បទពិសោធ និងមេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រងដឹកនាំ ការរៀបចំ និងធ្វើផែនការក្នុងវិស័យអប់រំមកដល់ខ្ញុំបាទផ្ទាល់និងមិត្តរួមជំនាន់ដទៃទៀតដូចៗគ្នា និងស្មើៗគ្នា។

ម្យ៉ាងវិញទៀត ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំង១១ នៅក្នុងខេត្តកណ្តាល និង គណៈគ្រប់គ្រងវិទ្យាល័យជ្រើសទាំង១១ ដែលបានជួយសហការ សម្របសម្រួល ព្រមទាំងចំណាយពេលចូលរួមផ្តល់ទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

បន្ទាប់មក ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជាអនេកកប្បការដល់ **ឯកឧត្តម ឆៀ សុផន** ជាគ្រូដឹកនាំបង្គោល ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត ផ្តល់ជាឯកសារនិងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំបាទទទួលបានជោគជ័យ និង ធានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណផងដែរដល់ **លោកបណ្ឌិត ឈាង សទ្ធារ៉ា** ជាគ្រូដឹកនាំរងដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង ចែករំលែកបទពិសោធន៍ និងពន្យល់ណែនាំចំណុចគន្លឹះល្អៗក្នុងការសរសេរនិក្ខេបបទ ដល់រូបខ្ញុំបាទ រហូតដល់សម្រេចបានលទ្ធផលល្អប្រសើរ។

មួយវិញទៀត ខ្ញុំបាទសូមថ្លែងនូវការដឹងគុណចំពោះ ក្រុមគ្រួសាររបស់ខ្ញុំ ដែលបានផ្តល់ពេលវេលា និងប្រាក់កាស ព្រមទាំងជំរុញឱ្យខ្ញុំបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំរហូតបាន បញ្ចប់នូវការសរសេរនិក្ខេបបទនេះ និងសូមអរគុណផងដែរដល់មិត្តរួមថ្នាក់ទាំងអស់ដែលសិក្សាថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលតែងតែផ្តល់ភាពសប្បាយរីករាយ ចែករំលែក ចំណេះដឹង បទពិសោធន៍ និងព័ត៌មានផ្សេងៗ និងមានទំនាក់ទំនងគ្នាយ៉ាងល្អ ដែលកាន់តែជំរុញឱ្យខ្ញុំ មានទឹកចិត្តសិក្សារៀនសូត្ររហូតដល់បញ្ចប់ការសិក្សា។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម នៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល មានគោលបំណងសិក្សាពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមដែលបាននឹងកំពុងអនុវត្តបច្ចុប្បន្ន។ ការសិក្សាស្រាវជ្រាវនេះក៏សិក្សាផងដែរអំពីផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តមដោយផ្អែកលើលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ដើម្បីទទួលបានទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរសម្រាប់សម្ភាសន៍ជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំង១១ ក្នុងខេត្តកណ្តាល និងគណៈគ្រប់គ្រងវិទ្យាល័យចំនួន១១នៅក្នុងក្រុង/ស្រុកទាំង១១ ហើយទិន្នន័យត្រូវបានបកស្រាយតាមបែបគុណវិស័យ។

លទ្ធផលនៃការស្រាវជ្រាវតាមចំនួនសំណាកបង្ហាញថា ការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តកណ្តាលគឺមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅឡើយទេដោយនៅខ្វះគ្រូបង្រៀនកម្រិតឧត្តមជាច្រើននាក់ទៀត។ ជាក់ស្តែងក្នុងចំណោមវិទ្យាល័យដែលបានជ្រើសរើសចំនួន១១ មាន១០វិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តម ហើយ ១០ វិទ្យាល័យ ក្នុងចំណោម ២៩ វិទ្យាល័យ ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមគឺត្រូវការគ្រូបង្រៀនកម្រិតឧត្តមរហូតដល់ទៅ៦០នាក់។ ជាមួយគ្នានេះដែរ កង្វះគ្រូបង្រៀនកម្រិតឧត្តមបានធ្វើឱ្យមានបញ្ហាប្រឈមយ៉ាងខ្លាំងដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពអប់រំកម្រិតវិទ្យាល័យ ក្នុងខេត្តកណ្តាលគឺវិទ្យាល័យនានាដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តនេះ ទទួលបានលទ្ធផលមិនសូវល្អក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

សរុបសេចក្តីមក ទោះបីជាមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យព្យាយាមចាត់វិធានការក្នុងការដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្តមក្តី ក៏ក្រសួងអប់រំ យុវជន និងកីឡាគួរតែយកចិត្តទុកលើបញ្ហានេះ ពីព្រោះវាជាបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់ដើម្បីឱ្យស្របទៅនឹងគោលដៅកំណែទម្រង់វិស័យអប់រំ។

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ........ i

លិខិតបញ្ជាក់ ........ ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii

សេចក្តីថ្លែងអំណរគុណ ........ iv

មូលន័យសង្ខេប ........ vi

មាតិកា ........ vii

បញ្ជីតារាង ........ xi

បញ្ជីក្រាប ........ xii

ជំពូកទី១ ........ 1

សេចក្តីផ្តើម ........ 1

១.១.សាវតារនៃការស្រាវជ្រាវ ........ 1

១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 3

១.៣.គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤.សំណួរស្រាវជ្រាវ ........ 5

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ 5

១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 5

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 6

ជំពូកទី១៖ សេចក្តីផ្តើម ........ 6

ជំពូកទី២៖ រំលឹកទ្រឹស្តី ........ 6

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 6
**ជំពូកទី៤៖ លទ្ធផល និង ការពិភាក្សា** ........ 6
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង សំណូមពរ** ........ 7
**ជំពូកទី២** ........ 8
**រំលឹកទ្រឹស្តី** ........ 8
**២.១.និយមន័យ** ........ 8
២.១.១.អត្ថន័យនៃពាក្យ ........ 8
២.១.២.ទស្សនៈផ្សេងៗស្តីអំពីការគ្រប់គ្រងធនធានមនុស្ស ........ 9
**២.២.គោលនយោបាយស្តីធនធានមនុស្សក្នុងវិស័យអប់រំ** ........ 10
**២.៣.គោលនយោបាយស្តីពីគ្រូបង្រៀន** ........ 11
**២.៤.លក្ខខណ្ឌដើម្បីក្លាយជាគ្រូបង្រៀនកម្រិតឧត្តម** ........ 12
២.៤.១.ព្រះរាជក្រឹត្យស្តីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ ........ 12
២.៤.២.ព្រះរាជក្រឹត្យស្តីពីលក្ខខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ........ 12
២.៤.៣.សេចក្តីណែនាំស្តីពីការប្រឡងជ្រើសចូលក្របខ័ណ្ឌគ្រូបង្រៀន ........ 13
២.៤.៤.សេចក្តីជូនដំណឹងលេខ៣១៣០ អយក.បល ........ 13
**២.៥.ស្ថានភាពអប់រំនៅកម្ពុជា** ........ 14
**២.៦.គោលការណ៍ណែនាំកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ** ........ 15
**២.៧.សេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀន** ........ 17
២.៧.១.ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ ........ 17
២.៧.២.ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន ........ 20
**២.៨.ផលប៉ះពាល់នៃកង្វះគ្រូបង្រៀន** ........ 22

**២.៩.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមវិទ្យាល័យនានាក្នុងខេត្តកណ្តាល ឆ្នាំសិក្សា២០១៧-២០១៨** ........ 22
**២.១០.ស្ថានភាពទូទៅរបស់គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ)** ........ 23
**២.១១.តម្រូវការគ្រូបង្រៀនកម្រិតឧត្តមសម្រាប់ឆ្នាំសិក្សា២០១៩-២០២០** ........ 23
**ជំពូកទី៣** ........ 24
**វិធីសាស្ត្រស្រាវជ្រាវ** ........ 24
**៣.១.ការប្រមូលទិន្នន័យ** ........ 24
**៣.២.ទីតាំងនៃការស្រាវជ្រាវ** ........ 24
**៣.៣.ការជ្រើសរើសភាគសំណាក** ........ 25
**៣.៤.ឧបករណ៍ក្នុងការស្រាវជ្រាវ** ........ 25
**៣.៥.ដំណាក់កាលនៃការប្រមូលទិន្នន័យ** ........ 27
**៣.៦.ការវិភាគទិន្នន័យ** ........ 28
**៣.៧.ក្រមសីលធម៌នៃការស្រាវជ្រាវ** ........ 28
**ជំពូកទី៤** ........ 30
**លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា** ........ 30
**៤.១.អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ** ........ 30
**៤.២.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំមន្ទីរអប់រំ** ........ 30
៤.២.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យ ........ 32
៤.២.២.មូលហេតុលើសតាមមុខវិជ្ជា ........ 33
៤.២.៣.បញ្ហាប្រឈមចំពោះដោយសារបញ្ហាខ្វះគ្រូបង្រៀនកម្រិតឧត្តម ........ 33
៤.២.៤.បញ្ហាប្រឈមចំពោះបញ្ហាលើសគ្រូបង្រៀនតាមមុខវិជ្ជា ........ 33
៤.២.៥.វិធានដោះស្រាយបញ្ហាប្រឈមដោយសារខ្វះគ្រូបង្រៀនកម្រិតឧត្តម ........ 34

៤.២.៦.វិធានដោះស្រាយបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជា ........ 34
**៤.៣.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំការិយាល័យអយក ក្រុង/ស្រុក** ........ 34
៤.៣.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យ ........ 41
៤.៣.២.មូលហេតុលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជានៅតាមវិទ្យាល័យ ........ 42
៤.៣.៣.បញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តម ........ 43
៤.៣.៤.បញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជា ........ 43
៤.៣.៥.វិធានការដោះស្រាយបញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ........ 44
៤.៣.៦.វិធានការដោះស្រាយបញ្ហាបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម ........ 45
**៤.៤.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងវិទ្យាល័យ** ........ 45
៤.៤.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ........ 51
៤.៤.២.មូលហេតុលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជាខ្លះ ........ 52
៤.៤.៣.បញ្ហាប្រឈម និងផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តម ........ 53
៤.៤.៦.ដំណោះស្រាយបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជា ........ 58
**ជំពូកទី៥** ........ 61
**សេចក្ដីសន្និដ្ឋាន និងសំណូមពរ** ........ 61
**ឯកសារយោង** ........ 64
**ឧបសម្ព័ន្ធ** ........ 67

# បញ្ជីតារាង

តារាង៤.១. ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ ..........................................30

តារាង៤.២. ស្ថិតិវិទ្យាល័យ និងចំនួនគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តកណ្ដាល ................................31

តារាង ៤.៣.វិទ្យាល័យដែលមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមនៅតាមក្រុង/ស្រុកទាំង១១ ............36

# បញ្ជីក្រាប

ក្រាប ១ ភេទរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 34
ក្រាប២ អាយុរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 35
ក្រាប៣ តួនាទីរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 36
ក្រាប៤ តំបន់ដែលវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តមស្ថិតនៅ នៅក្នុងក្រុងស្រុកទាំង១០ ........ 40
ក្រាប៥ វិធានការក្នុងការចាត់តាំងបន្តគ្រូចេញថ្មីរបស់ការិយាល័យអយក ក្រុង/ស្រុក ........ 41
ក្រាប៦ ភេទរបស់គណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 45
ក្រាប៧ តួនាទីរបស់គណៈគ្រប់គ្រងសាលាដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 46
ក្រាប៨ អាយុរបស់គណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្តល់បទសម្ភាសន៍ ........ 46
ក្រាប៩ តម្រូវការ(ខ្វះ) គ្រូបង្រៀនកម្រិតឧត្តមតាមវិទ្យាល័យ ........ 47
ក្រាប១០ តម្រូវការគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យតាមមុខវិជ្ជា ........ 48
ក្រាប១១ គ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការ និងលើសតាមមុខវិជ្ជា ........ 49
ក្រាប១២ ទីតាំងវិទ្យាល័យទាំងដែលបានជ្រើសរើសទាំង១១ ........ 50
ក្រាប១៣ ការសាកសួរព័ត៌មានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមតាមវិទ្យាល័យរបស់មន្ទីរ មុននឹងបញ្ជូនគ្រូថ្មីចូល ........ 51
ក្រាប១៤ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាលឆ្នាំសិក្សា២០១៧-២០១៨ និង២០១៨-២០១៩ ........ 54
ក្រាប១៥ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៧-២០១៨ នៅវិទ្យាល័យគោលដៅ ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម ........ 55
ក្រាប១៦ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាល័យគោលដៅដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម ........ 56

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១.សារតារនៃការស្រាវជ្រាវ

នៅលើសកលលោកយើងនេះ ការអប់រំគឺជាវិស័យអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់ សំខាន់បំផុត។ ការអប់រំជាប់ទាក់ទងទៅនឹងសេដ្ឋកិច្ច នយោបាយ ប្រព័ន្ធអប់រំ និងកម្មវិធីគោលនយោបាយអប់រំ (សាខន, ២០១៧)។

ការយកចិត្តទុកដាក់ទៅលើវិស័យអប់រំ គឺដើម្បីឱ្យប្រទេសមួយទទួលបានធនធានមនុស្សប្រកបដោយគុណភាពដើម្បីជាកម្លាំងចលករក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។

រាជរដ្ឋាភិបាលកម្ពុជា បានតម្កល់ការអភិវឌ្ឍធនធានមនុស្សក្នុងមុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ ដែលនេះជាគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិត និងបញ្ញាញាណដ៏ឈ្លាសវៃបំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានមនុស្ស និងក្នុងគោលដៅផលិតធនធានមនុស្សប្រកបដោយមូលធនបញ្ញា ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ យុទ្ធសាស្ត្រកំណែទម្រង់ និងគោលការណ៍កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាជាបន្តបន្ទាប់។ ជាក់ស្តែងក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឆ្នាំ ២០១៨ ដល់ ២០២៣ ដែលមានចក្ខុវិស័យ កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ការអភិវឌ្ឍធនធានមនុស្សសម្រាប់បម្រើប្រទេសជាតិជារឿងសំខាន់ ប៉ុន្តែការប្រើប្រាស់ ការគ្រប់គ្រង ការចាត់ចែងអ្នកបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសគ្រូបង្រៀន គឺរឹតតែសំខាន់ទៅទៀត។ ដើម្បីឱ្យការងារនេះទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨-២០២៣ ដែលក្នុងយុទ្ធសាស្ត្រនេះមាន

យុទ្ធសាស្ត្រវេងចម្បងៗចំនួន៤គឺ ៖ ១.កំណែទម្រង់ការគ្រប់គ្រងអប់រំ សំដៅដល់កំណែទម្រង់ការគ្រប់គ្រងការសិក្សា កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ២.កំណែទម្រង់ឧត្តមសិក្សា ៣.កំណែទម្រង់ការអភិវឌ្ឍយុវជន ៤.កំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។

ទន្ទឹមនេះ ក្រសួងក៏បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩ ដល់ ២០២៣ ដើម្បីបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ (ធានាឱ្យបាននូវការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ ព្រមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា) ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣, ២០១៩)។ ក្នុងផែនការយុទ្ធសាស្ត្រនេះត្រង់ជំពូកទី៤ គឺនិយាយអំពី យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាដែលមាន១០ចំណុច ហើយចំណុចទី៤ និយាយអំពីយុទ្ធសាស្ត្រកំណែទម្រង់គ្រប់គ្រងអប់រំ។ ក្នុងយុទ្ធសាស្ត្រកំណែទម្រង់គ្រប់គ្រងអប់រំមានមានសមាសធាតុ៤ ដែលក្នុងនោះមានសមាសធាតុមួយគឺកំណែទម្រង់ការគ្រប់ធនធានមនុស្ស។ កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងផែនការយុទ្ធសាស្ត្រនេះ គឺបានលើកយកនូវសកម្មភាពជាច្រើនដើម្បីអនុវត្តដូចជា អនុវត្តវិធានការកំណែទម្រង់បៀវត្ស ដាក់ចេញវិធានការដើម្បីពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងបុគ្គលិក បន្តជំរុញការអនុវត្តវិធានការពង្រាយគ្រូបង្រៀនពីសាលាលើសគ្រូបង្រៀនទៅសាលាខ្វះគ្រូជាដើម។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាការគ្រប់គ្រងធនធានមនុស្សគឺពិតជាមានសារសំខាន់ណាស់ក្នុងការជួយឱ្យវិស័យអប់រំមានការអភិវឌ្ឍ។ ជាមួយគ្នានេះដែរ តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅមធ្យមសិក្សាទុតិយភូមិក៏ជាផ្នែកមួយដ៏សំខាន់ផងដែរក្នុងការអភិវឌ្ឍវិស័យអប់រំ ពីព្រោះវាជាផ្នែកមួយស្ថិតនៅក្នុងការងារគ្រប់គ្រងធនធានមនុស្ស។

ក្នុងការគ្រប់គ្រងអ្នកបណ្តុះបណ្តាលធនធានមនុស្សនេះដែរ ក្រសួងអប់រំ យុវជន និងកីឡាបាន រៀបចំគោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ឆ្នាំ ២០១៨ ដល់ ២០២៣ ដែលក្នុងគោលការណ៍នេះ មានចំណុចសំខាន់ៗជាច្រើន ហើយក្នុងនោះមាន ចំណុចមួយនិយាយអំពីការពង្រាយគ្រូបង្រៀនពីសាលាលើសទៅតំបន់ខ្វះគ្រូ ដែលផ្តោតសំខាន់លើពីរ ចំណុចគឺ ការពង្រាយគ្រូក្របខ័ណ្ឌចាស់ និងការពង្រាយគ្រូបង្រៀនចេញថ្មី (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៩)។

ជាមួយគ្នានេះដែរ ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀនដែលជាអ្នកអប់រំគេ ក្រសួង អប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំលេខ ៥៣ អយក. សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១០១៩ ដោយបានដាក់ចេញនូវវិធានការសំខាន់ៗចំនួនបីគឺ ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ ការ ដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន និងការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន (សេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀន, ២០១៩)។

ការផ្គត់ផ្គង់គ្រូបង្រៀនគឺផ្នែកមួយនៃការគ្រប់គ្រងអ្នកបណ្តុះបណ្តាលធនធានមនុស្ស ឬគ្រប់គ្រង ធនធានមនុស្សក្នុងវិស័យអប់រំ។ ការផ្គត់ផ្គង់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ និងសមស្របតាមតម្រូវការគឺពិត ជាមានសារៈសំខាន់ណាស់ក្នុងដំណើរការបណ្តុះបណ្តាលធនធានមនុស្សឱ្យទទួលបានជោគជ័យ។

តាមរយៈការលើកឡើងខាងលើបង្ហាញថា តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនជាការងារដ៏សំខាន់ មួយរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលគួរតែយកចិត្តដាក់មិនអាចមើលរំលងបាន។

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងអាទិភាពមួយក្នុងចំណោមក្រសួងអាទិភាពនានាដែល ត្រូវបានរាជរដ្ឋាភិបាល បានផ្តល់អាទិភាពក្នុងការទទួលធនធាននានា ដូចជាៈ ថវិកាជាតិ ក្របខ័ណ្ឌមន្ត្រី រាជការថ្មី និងគ្រូបង្រៀនជាប់កិច្ចសន្យាជាដើម។ ក្នុងរង្វង់ប្រាំពីរឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានផ្តល់

ក្របខ័ណ្ឌមន្ត្រីរាជការជ្រើសរើសថ្មី ចំនួន ៣,៦០០ កន្លែង ចាប់តាំងពីឆ្នាំ២០១៤ រហូតមកដល់ឆ្នាំ ២០២០នេះ។ ក្រសួងបានបែងចែកក្របខ័ណ្ឌថ្មីទៅតាមតម្រូវការជាក់ស្តែងនៃក្របខ័ណ្ឌគ្រូបង្រៀនតាមភូមិសិក្សានីមួយៗ ជាក់ស្តែងនៅរៀងរាល់ឆ្នាំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) ត្រូវបានផ្តល់ក្នុងរង្វង់ពី ៨០០ កន្លែងទៅ ១,០០០ កន្លែង។

ដើម្បីធានាការបែងចែកក្របខ័ណ្ឌគ្រូបង្រៀនជ្រើសរើសថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ឱ្យមានប្រសិទ្ធភាព ដោះស្រាយកង្វះគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សានានា ជាពិសេសគ្រឹះស្ថានសិក្សាដែលស្ថិតនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ក្រសួងបានដាក់ចេញនូវគោលនយោបាយ និងវិធានការជាបន្តបន្ទាប់ ក្នុងការពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌដែលមានស្រាប់ ការបែងចែកគ្រូចេញថ្មី ការពង្រាយគ្រូបង្រៀនពីសាលាលើសគ្រូទៅសាលាខ្វះគ្រូបង្រៀន និងការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន ព្រមទាំងការផ្ទេរក្របខ័ណ្ឌគ្រូបង្រៀនទៅក្រសួង ស្ថាប័ននានា។ ទោះបីមានការខិតខំប្រឹងប្រែង និងការដាក់ចេញនូវវិធានការនានាក៏ដោយ ក៏សនិទានកម្មគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ នៅតែមានបញ្ហាចោទដដែល ជាពិសេសការលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន និងគ្រូបង្រៀនកម្រិតឧត្តមនៅទីប្រជុំជន និងការខ្វះគ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។ ជាមួយគ្នានេះ កង្វះគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) នឹងធ្វើឱ្យប៉ះពាល់ដល់គុណភាពរៀន និងបង្រៀនរបស់គ្រូ និងសិស្ស។

ក្នុងន័យនេះ ដើម្បីដោះស្រាយស្ថានភាពលើស ខ្វះគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) ពង្រឹងការបែងចែកគ្រូបង្រៀនកម្រិតឧត្តមឱ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីជីករកមូលហេតុចម្បងៗដែលនាំឱ្យការបែងចែកគ្រូបង្រៀនកម្រិតឧត្តមមិនឆ្លើយតបទៅនឹងតម្រូវការ និងផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តម អ្នកសិក្សាស្រាវជ្រាវបានសម្រេចយកប្រធានបទ **តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល** មកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ មានគោលបំណង៖

១.សិក្សាអំពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមដែលបាននឹងកំពុងអនុវត្តបច្ចុប្បន្ន ។

២. សិក្សាអំពីផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តម។

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនូវគោលបំណងខាងលើ សំណួរស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម៖

១.តើការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ)បច្ចុប្បន្ន បានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សាយ៉ាងដូចម្តេច?

២.តើកង្វះគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) នាំមកនូវបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥.សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះអាចជាព័ត៌មានសម្រាប់វិទ្យាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្វើជាមូលដ្ឋានក្នុងការកសាងផែនការក្របខ័ណ្ឌប្រចាំឆ្នាំ ការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន និងសម្រាប់អង្គភាព និងក្រសួងអប់រំ យុវជន និងកីឡា ធ្វើជាមូលដ្ឋានក្នុងការបែងចែកក្របខ័ណ្ឌគ្រូបង្រៀនជ្រើសរើសថ្មី រៀបចំគោលការណ៍ពង្រាយគ្រូបង្រៀនពីសាលាលើសទៅសាលាខ្វះ។ មួយវិញទៀតការសិក្សាស្រាវជ្រាវនេះនឹងក្លាយទៅជាទុនដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត។

## ១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីមានទិន្នន័យ ព័ត៌មានគ្រប់ជ្រុងជ្រោយក្នុងការវិភាគឱ្យបានស៊ីជម្រៅលើបញ្ហាប្រឈម និងផលប៉ះពាល់ដល់គុណភាពអប់រំ នៅកម្រិតវិទ្យាល័យ និងដោយលទ្ធភាពរបស់អ្នកសិក្សាស្រាវជ្រាវ ទើបអ្នកសិក្សាសម្រេចចិត្តជ្រើសរើសយក វិទ្យាល័យចំនួន១១ លើចំនួនវិទ្យាល័យ សរុប ៣៩ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល។ ក្នុងការចុះសិក្សាស្រាវជ្រាវ អ្នកសិក្សានឹងជួបសម្ភាសន៍ ថ្នាក់ដឹកនាំមន្ទីរ

អប់រំ យុវជន និងកីឡាខេត្តកណ្ដាល ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុកទាំង១១ និងគណៈគ្រប់គ្រងវិទ្យាល័យចំនួន១១ក្នុងខេត្តកណ្ដាល ដើម្បីធ្វើការសម្ភាសផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដោយប្រើទម្រង់កម្រងសំណួរស្រាវជ្រាវ។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកជា៥ ជំពូកដូចខាងក្រោមៈ

## ជំពូកទី១ៈ សេចក្ដីផ្ដើម

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ បានបង្ហាញពីសាវតារនៃការសិក្សាស្រាវជ្រាវ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ និង ចុងក្រោយ គឺ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ជំពូកទី២ៈ រំលឹកទ្រឹស្ដី

អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្ដីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ និងឯកសារផ្សេងៗ ដែលមានខ្លឹមសារទាក់ទងទៅនឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះ ដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងក្នុងនិក្ខេបបទសម្រាប់ស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីឡើង។

## ជំពូកទី៣ៈ វិធីសាស្ត្រស្រាវជ្រាវ

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីឧបករណ៍សម្រាប់ស្រាវជ្រាវ វិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យ វិធីសាស្ត្រក្នុងការជ្រើសរើសភាគសំណាក និង វិធីសាស្ត្រវិភាគទិន្នន័យ។

## ជំពូកទី៤ៈ លទ្ធផល និង ការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ និងស៊ីជម្រៅ ដើម្បីរកឱ្យឃើញពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមពិតប្រាកដ នៅមធ្យមសិក្សាខេត្តកណ្ដាល និងផលប៉ះពាល់ចម្បងៗដល់គុណភាពអប់រំ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង សំណូមពរ**

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋាន ទៅលើគ្រប់ចំណុចដែលបានវិភាគខាងលើ និងលើកជាសំណូមពរដើម្បីឱ្យក្រសួងអប់រំ យុវជន និងកីឡាមានទិន្នន័យច្បាស់លាស់សម្រាប់រៀបចំធ្វើផែនការក្របខ័ណ្ឌប្រចាំឆ្នាំ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១.និយមន័យ

### ២.១.១.អត្ថន័យនៃពាក្យ

គ្រូ មានន័យថា អ្នកដែលមានចិត្តធ្ងន់ អ្នកដែលគេគួរគោរព ពោលគឺ អ្នកបង្ហាត់ បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗដល់សិស្ស (ជួន ណាត, ១៩៦៧)។

**គ្រូបង្រៀន** សំដៅដល់ បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជន ដែលមានអាជ្ញាប័ណ្ណអប់រំ (អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, ២០០៨)។

**គ្រូបង្រៀនកម្រិតឧត្តម**(គ្រូវិទ្យាល័យ) គឺជាគ្រូបង្រៀនដែលបង្រៀននៅវិទ្យាល័យដោយទទួលបានការតែងតាំងដោយព្រះរាជក្រឹត្យថាបានក្លាយជាគ្រូបង្រៀនកម្រិតឧត្តម។

**គ្រូបង្រៀនកម្រិតឧត្តម** គឺជាមន្ត្រីរាជការដែលមានប្រភេទក្របខ័ណ្ឌ ក (ព្រះរាជក្រឹត្យស្តីគោលការណ៍រួមនៃការរៀបចំមុខងារសារណៈ, ១៩៩៧)។

**គ្រូបង្រៀនកម្រិតឧត្តម** គឺជាគ្រូបង្រៀនដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យ លេខ ជសរកត ១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ។ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡារួមមានមន្ត្រីបច្ចេកទេស ខាងគរុកោសល្យ និងបច្ចេកទេសផ្សេងទៀតដែលបានបណ្តុះបណ្តាល និងបម្រើការងារនៅតាមគ្រឹះស្ថានសាធារណៈមធ្យមសិក្សាចំណេះទូទៅ មធ្យមសិក្សាបច្ចេកទេស ឧត្តមសិក្សា និងអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុងនៃក្រសួងអប់រំ យុវជន និងកីឡា។ គ្រូបង្រៀនកម្រិតឧត្តមមានមុខងារក្នុងតំណែងជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវ និងមុខតំណែងគ្រប់គ្រង។ ក្របខ័ណ្ឌនេះមានឋានន្តរស័ក្តិចំនួន៣ថ្នាក់ និងមានមុខតំណែងអតិបរមា ជាសាកល

វិទ្យាធិការ អគ្គនាយក អគ្គាធិការជាដើម។ (ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃគ្រូបង្រៀនកម្រិតឧត្តម, ២០០១)។

**តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀន** គឺជាផ្នែកមួយស្ថិតនៅក្នុងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ដែលសំដៅដល់ការរៀបចំចាត់ចែងធនធានមនុស្សក្នុងវិស័យអប់រំ ពោលគឺរៀបចំចាត់ចែងគ្រូបង្រៀនឱ្យបានសមស្រប ដើម្បីឱ្យក្រសួងអប់រំ យុវជន និងកីឡាមានដំណើរការទៅដោយរលូន។

**២.១.២.ទស្សនៈផ្សេងៗស្តីអំពីការគ្រប់គ្រងធនធានមនុស្ស**

ការគ្រប់គ្រងធនធានមនុស្ស សំដៅដល់ដំណើរការអនុវត្តការចាត់ចែង និងគ្រប់គ្រងមន្ត្រី ដើម្បីសម្រេចនូវលទ្ធផលរំពឹងទុករបស់មន្ត្រី និងគោលដៅរបស់អង្គភាព។ ការគ្រប់គ្រងធនធានមនុស្ស រួមមានការបែងចែកការងារ និងការធ្វើផែនការធនធានមនុស្ស ការគ្រប់គ្រងគុណផល ការជ្រើសរើស និងការតែងតាំង ការផ្លាស់ប្តូរស្ថានភាពមន្ត្រី វត្តមាន និងការឈប់សម្រាក ក្រមសីលធម៌ និងវិន័យ ការលាឈប់ពីក្របខ័ណ្ឌមុខងារសាធារណៈ និងការផ្តល់ការលើកទឹកចិត្តមន្ត្រី (thmeythmey, 2017)។

ការគ្រប់គ្រងធនធានមនុស្ស គឺជាដំណើរការរួមបញ្ចូលគ្នានូវសកម្មភាពមួយចំនួនសម្រាប់ អ្នកគ្រប់គ្រងអនុវត្តន៍ដូចជាការកសាងផែនការធនធានមនុស្ស ការទាក់ទាញបុគ្គលិកដែលមានសមត្ថភាពឱ្យមកបម្រើការងារជាមួយអង្គភាព ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក ការថែរក្សាបុគ្គលិកឱ្យធ្វើការងារជាមួយអង្គភាពបានយូរអង្វែង និង ជំរុញលើកទឹកចិត្តឱ្យបុគ្គលិកអនុវត្តន៍ការងារអស់ពីសមត្ថភាពរបស់ពួកគេ (សាំងលីននិងសោភា, ២០១៨)។

ការគ្រប់គ្រងធនធានមនុស្ស គឺជាវិធីសាស្ត្រសមស្របក្នុងការគ្រប់គ្រងមនុស្សប្រកបដោយប្រសិទ្ធភាពនៅក្នុងក្រុមហ៊ុន ឬអង្គភាពដែលពួកគេជួយធ្វើអាជីវកម្មឱ្យទទួលបានអត្ថប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែង (WIKIPEDIA, 2020)។

ការគ្រប់គ្រងធនធានមនុស្ស គឺជាពាក្យដែលត្រូវបានប្រើដើម្បីពិពណ៌នាអំពីប្រព័ន្ធផ្លូវការបង្កើតឡើងសម្រាប់ការគ្រប់គ្រងមនុស្សនៅក្នុងអង្គភាពមួយ (Inc., 2020)។

ការគ្រប់គ្រងធនធានមនុស្សគឺជាវិធីសាស្ត្របែបយុទ្ធសាស្ត្រនិងមានទំនាក់ទំនងគ្នា ទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិដែលមានតម្លៃបំផុតរបស់អង្គភាពពេលគឺមនុស្សដែលធ្វើការនៅទីនោះ គឺជាអ្នកដែលរួមចំណែកទាំងលក្ខណៈជាបុគ្គល និងលក្ខណៈរួមដើម្បីសម្រេចបាននូវគោលបំណងរបស់អង្គភាព (Sharon&Swapnalekha, 2012)។

ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំគឺជាសំណុំនៃការអនុវត្ត និងវិធីសាស្ត្រនៃការធ្វើសមាហរណកម្ម និងរក្សាបុគ្គលិកបង្រៀននៅក្នុងសាលាដើម្បីឱ្យសាលាអាចសម្រេចគោលបំណងរបស់ពួកគេដើម្បីបំពេញតាមគោលដៅដែលពួកគេបានបង្កើតឡើង។ វាគឺជាការជំរុញទឹកចិត្ត និងការសម្របសម្រួលនៃសកម្មភាព និងការខិតខំប្រឹងប្រែងរបស់គ្រូនៅសាលាដើម្បីទទួលបានលទ្ធផលអតិបរមាពីពួកគេ និងដើម្បីសម្រេចបាននូវគោលដៅនៃការអប់រំប្រកបដោយប្រសិទ្ធភាព (Chinyere, 2018)។

## ២.២.គោលនយោបាយស្តីធនធានមនុស្សក្នុងវិស័យអប់រំ

នៅខែវិច្ឆិកា ឆ្នាំ២០១២ ក្រសួងអប់រំ យុវជន និងកីឡាបានចេញគោលនយោបាយស្តីធនធានមនុស្សក្នុងវិស័យអប់រំ ដែលក្នុងគោលនយោបាយនេះមានចំណុចសំខាន់ៗមួយចំនួនស្តីអំពីការគ្រប់គ្រងធនធានមនុស្ស។ គោលនយោបាយនេះមានគោលដៅសំខាន់ចំនួនបួន ហើយក្នុងនោះមានគោលដៅសំខាន់ពីរដែលផ្តោតលើការគ្រប់គ្រងធនធានមនុស្សគឺ បង្កើនប្រសិទ្ធភាពការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ និងសនិទានកម្មលើដំណើរការគ្រប់គ្រង ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានមនុស្សក្នុងវិស័យអប់រំ។ ជាមួយគ្នានេះដែរ គោលនយោបាយនេះក៏បានលើកឡើងពីយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំផងដែរគឺ ពង្រឹង និងធ្វើទំនើបកម្មការកសាងផែនការធនធានមនុស្ស ដោយផ្តោតលើចំណុចសំខាន់ជាច្រើនដូចជា

- បង្កើនប្រសិទ្ធភាពប្រព័ន្ធប្រមូល គ្រប់គ្រង និងវិភាគទិន្នន័យធនធានមនុស្ស
- ធ្វើផែនការវិភាគតម្រូវការ ការផ្គត់ផ្គង់បុគ្គលិកអប់រំ
- ពង្រឹង និងជំរុញការកសាងផែនការធនធានមនុស្សតាមអង្គភាព ស្ថាប័នអប់រំឱ្យមានលក្ខណៈវិទ្យាសាស្ត្រ

- បង្កើនកិច្ចសហការល្អជាមួយអង្គភាពផលិតទិន្នន័យព័ត៌មាន
- រៀបចំបុគ្គលិកអប់រំឱ្យបំពេញការងារចំកន្លែង ទាន់ពេល ចំជំនាញ ស្របតាមការពណ៌នាមុខតំណែង លក្ខណៈសម្បត្តិមុខតំណែង និងអាទិភាពតម្រូវការ។

## ២.៣.គោលនយោបាយស្តីពីគ្រូបង្រៀន

គោលនយោបាយស្តីពីគ្រូបង្រៀនត្រូវបានបង្កើតឡើងកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣។ នយោបាយនេះមានយុទ្ធសាស្រ្តសំខាន់ជាច្រើន ដែលក្នុងនោះមានយុទ្ធសាស្រ្តមួយនិយាយអំពីការបំពេញតម្រូវការគ្រូបង្រៀនរបស់គ្រឹះស្ថានសិក្សាគឺ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សាដោយផ្តោតលើចំណុចសំខាន់ៗជាច្រើនដូចជា៖

- ធ្វើទំនើបកម្មផែនការតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់បណ្តុះបណ្តាលមុនពេលបម្រើការងារ
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់ និងតាមគោលការណ៍
- លើកកម្ពស់ការគ្រប់គ្រង និងរៀបចំក្របខ័ណ្ឌគ្រូបង្រៀន
- លើកកម្ពស់ដំណើរការនិងនិតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អ សម្រាប់ជានានិរន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀននៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិសិក្សារបស់សិស្ស។

## ២.៤.លក្ខខណ្ឌដើម្បីក្លាយជាគ្រូបង្រៀនកម្រិតឧត្តម

### ២.៤.១.ព្រះរាជក្រឹត្យស្ដីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ

តាមព្រះរាជក្រឹត្យស្ដីគោលការណ៍រួមនៃការរៀបចំមុខខារសារណៈ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៧ ក្នុងមាត្រា ៣ បានកំណត់ថាកម្រិតអប្បរមានៃការបណ្ដុះបណ្ដាល ដើម្បីអាចបញ្ចូលក្របខ័ណ្ឌក្នុងប្រភេទ ក គឺសញ្ញាបត្រមធ្យមសិក្សាកម្រិត២ បូក៤ឆ្នាំនៃការសិក្សា ដោយមានសញ្ញាបត្រ។ លក្ខខណ្ឌដោយឡែកខ្លះអាចប្រសិនបើចាំបាច់ តម្រូវកម្រិតអប្បរមានៃការបណ្ដុះបណ្ដាលស្មើឬលើសសញ្ញាបត្រមធ្យមសិក្សាកម្រិត២ បូក៦ឆ្នាំនៃការសិក្សា ដោយមានសញ្ញបត្រ។ ក្នុងករណីនេះត្រូវមានផ្ដល់នូវការបន្ថែមសន្ទស្សន៍បៀវត្ស។

### ២.៤.២.ព្រះរាជក្រឹត្យស្ដីពីលក្ខខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ត្រូវធ្វើឡើងតាមការប្រឡងជ្រើសរើសក្នុងចំណោមបេក្ខជនជា និស្សិត ឬជាមន្ត្រីរាជការរបស់ក្រសួងអប់រំ យុវជន និងកីឡា និង មន្ត្រីរាជការផ្សេងទៀត។ រីឯលក្ខខណ្ឌក្នុងការប្រឡងជ្រើសរើស សម្រាប់បេក្ខជនជានិស្សិតត្រូវមានអាយុយ៉ាងច្រើន៣០ឆ្នាំគិតដល់ថ្ងៃប្រឡង និងមានសញ្ញាបត្រទាបបំផុត បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល។ ចំណែកឯបេក្ខជនជាមន្ត្រីរាជការវិញ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

បេក្ខជនដែលបានប្រឡងជាប់មានឋានៈជាគរុនិស្សិតកម្រិតឧត្តម និងត្រូវបានទទួលការបណ្ដុះបណ្ដាលដំបូង ដែលរៀបចំឡើងដោយក្រសួង អប់រំ យុវជន និងកីឡា ។ ក្រោយចប់ការបណ្ដុះបណ្ដាល និងបានប្រឡងជាប់ គរុនិស្សិតត្រូវបានបែងឱ្យទៅបម្រើការនៅតាមខេត្ត ក្រុង ឬនៅថ្នាក់កណ្ដាល ដោយត្រូវឆ្លងកាត់កម្មសិក្សារយៈពេល១២ខែ សម្រាប់គ្រូបង្រៀនកម្រិតឧត្តមដែលជ្រើសរើសចេញពីនិស្សិត និងរយៈពេល៦ខែ សម្រាប់មន្ត្រីរាជការមកពីក្រសួងផ្សេង ទើបត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ ហើយការតាំងស៊ប់ក្នុងក្របខ័ណ្ឌគឺត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ចំណែកមន្ត្រីរាជការមកពីក្រសួងអប់រំ យុវជន និងកីឡាវិញមិនចាំបាច់ឆ្លងកាត់កម្មសិក្សាឡើយ។

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ គ្រូបង្រៀនកម្រិតឧត្តមត្រូវបានតែងតាំងឱ្យបំពេញមុខងារក្នុងមុខដំណែង ឬ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ហើយក៏អាចដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ឬ ក្រៅតំណែងទៀតផង។

គ្រូបង្រៀនកម្រិតឧត្តម ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល ហើយអាចបម្រើការដល់អាយុ៦០ឆ្នាំទើបចូលនិវត្តន៍។

## ២.៤.៣.សេចក្តីណែនាំស្តីពីការប្រឡងជ្រើសចូលក្របខ័ណ្ឌគ្រូបង្រៀន

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំមួយស្តីពីការប្រឡងជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀន ដោយបានលើកឡើងអំពីការប្រឡងជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) ដោយឱ្យវិទ្យាស្ថានជាតិអប់រំ សហការជាមួយនាយកដ្ឋានបុគ្គលិក និងអង្គភាពពាក់ព័ន្ធដើម្បីពិភាក្សាលើការបែងចែកតួលេខ រៀបចំសេចក្តីជូនដំណឹងស្តីពីការប្រឡងជ្រើសរើស រៀបចំការប្រឡង ដោយកំណត់លក្ខខណ្ឌជ្រើសរើសស្របតាមគោលការណ៍ណែនាំ បិទផ្សាយតារាងបែងចែកចំនួនជ្រើសរើស និងបញ្ជីតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជាឯកទេសរបស់សាលារៀននីមួយ និងទទួលពាក្យសុំចុះឈ្មោះប្រឡង។

## ២.៤.៤.សេចក្តីជូនដំណឹងលេខ៣១៣០ អយក.បល

កាលពីថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតលេខ ៣១៣០ .បល ដែលមានកម្មវត្ថុស្តីពីការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញា+១ ជំនាន់ទី២៥ ចំនួន១០០០នាក់ សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ តាមប្រព័ន្ធបណ្តុះបណ្តាល បរិញ្ញា+១ ។ ក្នុងលិខិតនេះ បានកំណត់នូវលក្ខខណ្ឌនៃការជ្រើសដោយមានលក្ខខណ្ឌសំខាន់ៗមួយចំនួនដូចជា បេក្ខជនត្រូវតែជានិស្សិតសុទ្ធសាធ ពុំទាន់មានការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ជាបុគ្គលិកក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡា និងមានសញ្ជាតិខ្មែរ មានជីវប្រវត្តិច្បាស់លាស់ មានសុខភាពល្អ មានសញ្ញាបត្រចាប់ពី

បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ ព្រមទាំងបានកំណត់អាយុសម្រាប់បេក្ខជនផង ដែរគឺ និស្សិតដែលមានការបណ្ដុះបណ្ដាលចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវលើកលែងអាយុ និស្សិតដែល មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូលត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ គិតត្រឹមថ្ងៃ ប្រឡង និស្សិតដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត៣៥ឆ្នាំគិត ដល់ថ្ងៃប្រឡង។

## ២.៥.ស្ថានភាពអប់រំនៅកម្ពុជា

ឯកសារក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៨ បាន លើកឡើងថា ការអប់រំរបស់កម្ពុជាមានការរីកចម្រើនខាងបរិមាណ ជាពិសេសនៅបឋមសិក្សា ប៉ុន្តែនៅ មធ្យមសិក្សាវិញ ទាំងបរិមាណ និងគុណភាពនៅតែមានបញ្ហា ដែលបណ្ដាលមកពីកត្តាជាច្រើន ជា ពិសេសខ្វះគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ នៅតំបន់ជួបការលំបាក។

កម្ពុជានៅតែប្រឈមនឹងការពង្រឹងគុណភាពគ្រូបង្រៀន រក្សាគ្រូបង្រៀននៅបម្រើការងារក្នុង មុខងារអប់រំបានយូរ ឬរហូតដល់ចូលនិវត្តន៍ ទាក់ទាញអ្នកមានឧបនិស្ស័យ ជាពិសេស សិស្សដែលមាន និទ្ទេសល្អៗឱ្យចូលបម្រើការងារជាគ្រូបង្រៀនក្នុងវិស័យអប់រំ។ ជាមធ្យម ក្រសួងអប់រំ យុវជន និងកីឡា បាត់បង់បុគ្គលិកអប់រំប្រមាណជាង២០០០នាក់ក្នុងមួយឆ្នាំ ដែលក្នុងនោះអ្នកចូលនិវត្តន៍មានប្រមាណ ១៥០០នាក់ លុបឈ្មោះចោលពីក្របខ័ណ្ឌចំនួន ៥០០នាក់ និងសុំផ្ទេរទៅក្រសួងផ្សេងៗ មានចំនួន ២០០នាក់។ កត្តាបាត់បង់បុគ្គលិកអប់រំ និងកត្តាខ្វះសិស្សពូកែៗមកចូលបម្រើក្នុងវិស័យអប់រំ ជាកង្វល់ របស់សាធារណៈ របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល។

ការស្រាវជ្រាវជាច្រើនពន្យល់ថា គ្រូបង្រៀនមានសញ្ញាបត្រកាន់តែខ្ពស់ ការបង្រៀនកាន់តែមាន គុណភាព។ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ភាគច្រើន គ្រូបង្រៀនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ+២។ ចំណែកនៅកម្ពុជា គ្រូបង្រៀនភាគច្រើនមិនទាន់មានបរិញ្ញាបត្រនៅឡើយ ទោះបីជាការបណ្ដុះបណ្ដាល គ្រូបង្រៀនមានការវិវត្តន៍ជាច្រើនក៏ដោយ។ គ្រូបង្រៀនមួយចំនួនដែលចូលក្នុងក្របខ័ណ្ឌអប់រំកាលពីឆ្នាំ ១៩៩២-១៩៩៣ មានសញ្ញាបត្រ ៨+១ (បង្រៀននៅថ្នាក់មត្តេយ្យ) ៨+២ (បង្រៀននៅកម្រិតបឋម

សិក្សា) ១១+២ (ថ្នាក់មធ្យមសិក្សាបឋមភូមិ) ១០+៤ និងបរិញ្ញាបត្រ (ថ្នាក់មធ្យមសិក្សាទុតិយភូមិ)។ ក្នុងឆ្នាំ២០១៦-២០១៧ ការបណ្តុះបណ្តាលគ្រូបង្រៀនអនុវត្តប្រព័ន្ធ ១២+២ទាំងអស់សម្រាប់គ្រប់កម្រិតសិក្សា លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិដែលអនុវត្តប្រព័ន្ធបរិញ្ញាបត្រ+១។

## ២.៦.គោលការណ៍ណែនាំកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ

### ការពង្រាយគ្រូបង្រៀនពីសាលាលើសទៅតំបន់ខ្វះគ្រូបង្រៀន

### ក.ការពង្រាយគ្រូបង្រៀនក្របខ័ណ្ឌចាស់

- ជំរុញការធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់កណ្តាល និងនៅរាជធានី ខេត្ត ជាប្រចាំដើម្បីតាមដានស្ថានភាពប្រែប្រួល (លើស ខ្វះ ) បុគ្គលិកអប់រំផ្នែករដ្ឋបាល និងគ្រូបង្រៀន តាមភូមិសិក្សា និងតាមជំនាញឯកទេស
- កែសម្រួលគោលការណ៍ស្តីពីការពង្រាយគ្រូបង្រៀន (ជាទម្រង់អនុក្រឹត្យ) ដោយរំលេចតម្រូវការជាមូលដ្ឋាន ទាំងថវិកា និងមិនមែនថវិកា ឱ្យបានគ្រប់ជ្រុងជ្រោយ តាមស្ថានភាពជាក់ស្តែងបច្ចុប្បន្ន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើសុពលភាពចំនួនសិស្សគ្រូ ពិនិត្យ និងតាមដានសាលាខ្វះ និងលើសគ្រូបង្រៀនជារៀងរាល់ឆ្នាំ ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំយន្តការអនុវត្តក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន ដើម្បីលើកទឹកចិត្តគ្រូបង្រៀន និងនាយកសាលារៀន ដើម្បីឱ្យគាត់ប្រើប្រាស់សមត្ថភាពក្នុងការអភិវឌ្ឍអាជីពដែលផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធលាភការ និងប្រព័ន្ធលើកទឹកចិត្ត
- អនុវត្តសាកល្បងគោលនយោបាយពង្រាយគ្រូបង្រៀន និងនាយកសាលាៈ គ្រូបង្រៀន និងនាយកសាលាគួរផ្លាស់ប្តូរទីកន្លែងធ្វើការក្នុងរាជធានី ខេត្តរៀងរាល់០៥ឆ្នាំម្តង
- ស្នើសុំគោលការណ៍ផ្តល់ប្រាក់កម្រៃធ្វើដំណើរ សម្រាប់គ្រូបង្រៀននៅតំបន់ជួបការលំបាក។

## ខ.ការពង្រាយគ្រូបង្រៀនចេញថ្មី

- កសាងគោលការណ៍ស្តីពីការពង្រាយគ្រូបង្រៀនចេញថ្មី ដោយតម្រូវឱ្យសិស្ស និស្សិត ដែលមានបំណងដាក់ពាក្យចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន និងគ្រឹះស្ថានសិក្សាត្រូវៈ
  - •ជ្រើសសាលារៀនដែលខ្វះគ្រូបង្រៀន ដោយសាមីខ្លួនអាចទៅបង្រៀននៅទីនោះបាន
  - •នាយកសាលារៀនត្រូវសម្ភាសន៍បេក្ខជន និងផ្តល់ចំណារយល់ព្រមទទួលនៅលើពាក្យសុំចុះឈ្មោះប្រឡង
  - •មានកិច្ចសន្យាបម្រើការងារនៅទីនោះ យ៉ាងតិច០៥ឆ្នាំ តំបន់វាលរាប និង០៣ឆ្នាំ តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល
- ក្រសួងធ្វើសេចក្តីណែនាំដើម្បីអនុវត្តចំណុចខាងលើ សម្រាប់ការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ ចាប់ពីឆ្នាំ២០១៩តទៅ
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងសាលារៀនទាំងអស់ ត្រូវបន្តគ្រប់គ្រងទិន្នន័យគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ និងមុខជំនាញឯកទេសដែលមានបច្ចុប្បន្ន និងត្រូវព្យាករពីតម្រូវការគ្រូបង្រៀន តាមប្រភេទក្របខ័ណ្ឌ និងមុខជំនាញឯកទេសសម្រាប់រយៈពេលខ្លី និងមធ្យម
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវធ្វើបញ្ជីឈ្មោះសាលារៀនដែលមានតម្រូវការគ្រូបង្រៀន និងតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជាឯកទេស ដើម្បីធ្វើសេចក្តីប្រកាសជូនដំណឹងដល់បេក្ខជនជ្រើសរើសនៅពេលដាក់ពាក្យចុះឈ្មោះប្រឡង
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវទទួលពាក្យសុំចុះឈ្មោះប្រឡង ហើយត្រូវបិទផ្សាយអង្គភាព/សាលារៀនដែលមានតម្រូវការគ្រូបង្រៀន

- គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ
- ក្រសួង នឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ ចុះឈ្មោះក្នុងប្រព័ន្ធព័ត៌មានវិទ្យា របស់ក្រសួងមុខងារសាធារណៈ ហើយស្នើគោលការណ៍ផ្តល់ក្របខ័ណ្ឌបណ្តោះអាសន្ន
- ក្រសួង នឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ផ្តល់ប្រាក់បៀវត្សមូលដ្ឋានដល់គរុសិស្សនិស្សិត បន្ទាប់ពីបានប្រឡងជាប់ និងបានចូលរៀននៅឆ្នាំទី១ ចំពោះកម្មវិធីបណ្តុះបណ្តាលរយៈពេល១ឆ្នាំ ចាប់ពីឆ្នាំទី២ ចំពោះកម្មវិធីបណ្តុះបណ្តាលរយៈពេល២ឆ្នាំ នឹងចាប់ពីឆ្នាំទី៣ ចំពោះកម្មវិធីបណ្តុះបណ្តាលរយៈពេល៤ឆ្នាំ។ ក្រៅពីនេះគឺអនុវត្តគោលការណ៍ផ្តល់អាហារូបករណ៍ដដែល។

## ២.៧.សេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀន

ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ចាប់ពីឆ្នាំសិក្សា ២០១៩-២០២០ ក្រសួងអប់រំ យុវជននិងកីឡាដាក់ចេញនូវវិធានការដូចខាងក្រោម៖

### ២.៧.១.ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ

- នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាងឬស្មើ៣ថ្នាក់
- ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យ និងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខ័ណ្ឌ និងតាមមុខជំនាញ និង ត្រូវសហការ

ជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខ័ណ្ឌឱ្យទៅដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន

- គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែលសាមីខ្លួនបានជ្រើសរើសដោយមិនអនុវត្តការផ្ដល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានីខេត្ត ចុះត្រួតពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន)
- ក្រសួង នឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្ដល់ក្របខ័ណ្ឌបណ្ដោះអាសន្ន
- ក្រសួង នឹងពិនិត្យស្នើគោលការណ៍ផ្ដល់ប្រាក់បៀវត្សមូលដ្ឋានដល់គរុសិស្ស និស្សិត បន្ទាប់ពីបានប្រឡងជាប់។

**ក.ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា**

- គ្រឹះស្ថានសិក្សានីមួយៗត្រូវធ្វើការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខ័ណ្ឌ និងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់មុននឹងលើកសំណើសុំគ្រូបង្រៀនបន្ថែមរួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរពេល។ល។
- ការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សត្រូវអនុលោមតាមសេចក្ដីណែនាំលេខ ២០ អយក.សណន ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា សេចក្ដីណែនាំលេខ ៤៩៨ មស.សណនស្ដីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ របស់ក្រសួងមុខងារសាធារណៈ
- គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញមិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងអនាគត

- គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីជានាថា បុគ្គលិក/គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមកនឹងបំពេញនូវតម្រូវការធនធានមនុស្សសម្រាប់បច្ចុប្បន្ន និងមិនសល់ក្នុងពេលអនាគត។

**ខ.ការរៀបចំផែនការក្របខ័ណ្ឌប្រចាំឆ្នាំ**

- អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហការគ្នាដើម្បីរៀបចំផែនការមេស្តីពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀន ដោយផ្អែកលើចំណោលសិស្ស
- ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខ័ណ្ឌ និងមរណជន
- រៀបចំសំណើសុំក្របខ័ណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូនក្រសួងមុខងារសាធារណៈ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

**គ.ការជ្រើសរើសបុគ្គលិកចូលក្របខ័ណ្ឌ**

- បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ
- បន្តប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មី ទៅតាមប្រភេទក្របខ័ណ្ឌ មុខវិជ្ជាជំនាញ
- ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្តដាច់ស្រយាល
- បន្តប្រឡងជ្រើសរើសបញ្ចូលក្របខ័ណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- ការជ្រើសរើសគ្រូបន្ថែម គួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំងកាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន

- ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ការប្រឡងជ្រើសរើសគ្រូក្របខ័ណ្ឌថ្មី គួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ការបែងចែកក្របខ័ណ្ឌថ្មីសម្រាប់ការប្រឡងជ្រើសរើសត្រូវរៀបចំបែងចែកតាមដំណាក់កាលៈ
  - បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខ័ណ្ឌប្រចាំឆ្នាំ ក្រសួងត្រូវប្រជុំពិនិត្យការបែងចែកតួលេខជាកញ្ចប់ឱ្យទៅដល់រាជធានី ខេត្តនីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិតមូលដ្ឋាន និងបឋមមត្តេយ្យសិក្សាដោយផ្អែកលើស្ថានភាពខ្វះជាក់ស្តែង
  - បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តនីមួយៗត្រូវយកទៅបែងចែក ឱ្យទៅដល់សាលារៀនដែលកំពុងខ្វះជាក់ស្តែងតាមប្រភេទក្របខ័ណ្ឌ និងទៅតាមមុខវិជ្ជាជំនាញចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម ដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវការឱ្យបានច្បាស់លាស់ និងលើកសំណើរមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច
  - បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវរៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យ និងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុវត្តការប្រឡងជ្រើសរើស។

## ២.៧.២.ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន

- ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ២៣ អយក.សណន ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបែងចែកបុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួនដូចខាងក្រោម)

- ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍
- គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើសត្រូវទៅបម្រើនៅទីនោះ
- បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសរួច
- គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្សឬស្នើលុបឈ្មោះចេញពីក្របខ័ណ្ឌភ្លាម។

**ក.សាលារៀនលើសគ្រូបង្រៀន**

**ករណីរាជធានីភ្នំពេញ**

- អនុវត្តសាកល្បងនៅរាជធានីភ្នំពេញ ដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀនដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀននៅជិតលំនៅដ្ឋានរបស់ពួកគាត់។

**ករណីខេត្តផ្សេងទៀត**

- បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
- ស្នើសុំគោការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
- សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

**ខ.សាលារៀនដែលខ្វះគ្រូបង្រៀន**

ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យ

សាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ការស្នើបញ្ចូលក្របខ័ណ្ឌ (ទាំងគ្រូក្របខ័ណ្ឌ និងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់គ្រងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព។

## ២.៨.ផលប៉ះពាល់នៃកង្វះគ្រូបង្រៀន

នៅពេលមានបញ្ហាកង្វះខាតគ្រូបង្រៀនគឺត្រូវរកគ្រូបង្រៀនមកជំនួស។ ប៉ុន្តែបើគ្រូបង្រៀនជំនួសនោះមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀន និងធ្វើឱ្យមានផលប៉ះពាល់ដល់ការសិក្សារបស់សិស្ស។ ការផ្លាស់ប្តូរ និងកង្វះគ្រូបង្រៀនគឺជាបញ្ហាសំខាន់បំផុតក្នុងការអប់រំ។ គ្រូបង្រៀនគឺជាអ្នកដែលមានឥទ្ធិពលទីមួយនៅក្នុងសាលារៀនលើសមិទ្ធិផលរបស់សិស្ស។ ការស្រាវជ្រាវបង្ហាញថាការបង្រៀនដែលមានគុណភាពអន់ធ្វើឱ្យរំខានដល់ការរៀនសូត្រ និងមានផលប៉ះពាល់អវិជ្ជមានដល់សមត្ថភាពរបស់សិស្សក្នុងការបញ្ចប់ការសិក្សា និងការត្រៀមខ្លួនចូលប្រឡូកក្នុងការងារ (LEARNING POLICY INSTITUTE, 2018)។ នៅក្នុងខេត្តកណ្តាល តាមលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់សិស្សក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះមានការកើនឡើង ប៉ុន្តែស្ថិតក្នុងកម្រិតមួយនៅមិនទាន់ល្អនៅឡើយ។ ការប្រើប្រាស់គ្រូបង្រៀនដែលគ្មានគុណវុឌ្ឍិច្រើន ជាចំណែកមួយដែលនាំឱ្យសិស្សទទួលបានលទ្ធផលប្រឡងមិនសូវល្អ (គីមហេង, ២០១៨)។

## ២.៩.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមវិទ្យាល័យនានាក្នុងខេត្តកណ្តាលឆ្នាំសិក្សា២០១៧-២០១៨

ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ក្នុងខេត្តកណ្តាលមានគ្រូបង្រៀនកម្រិតឧត្តមចំនួន៩៨៣នាក់ ដោយត្រូវការគ្រូបង្រៀនកម្រិតឧត្តមចំនួន ៣៣១នាក់ បន្ថែមទៀត ប៉ុន្តែក្នុងនោះក៏មានវិទ្យាល័យខ្លះលើសតម្រូវការផងដែរ។ ចំណែកមូលហេតុចម្បងដែលនាំឱ្យខ្វះ និងលើសគឺការផ្ទេរចេញ ផ្ទេរចូល តាម

សហព័ទ្ធ និងទៅរកកន្លែងទីប្រជុំជន។ កង្វះគ្រូបង្រៀនកម្រិតឧត្តមបានធ្វើឱ្យមានបញ្ហាប្រឈមសម្រាប់គណៈគ្រប់គ្រងក្នុងការចាត់ចែងគ្រូបង្រៀននៅតាមវិទ្យាល័យនានា ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម ប៉ុន្តែគណៈគ្រប់គ្រងសាលាបានចាត់វិធានការខ្លះៗដើម្បីដោះស្រាយបញ្ហាខាងលើ (គីមហេង, , ២០១៨)។

## ២.១០.ស្ថានភាពទូទៅរបស់គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ)

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ នៅទូទាំងប្រទេសខ្វះគ្រូបង្រៀនកម្រិតឧត្តមចំនួន៣៦៧៧នាក់ ក្នុងនោះខេត្តកណ្ដាលខ្វះចំនួន ២១២នាក់ លើកលែងតែរាជធានីភ្នំពេញដែលលើស៤៤២នាក់ (របាយការណ៍ស្តីពីស្ថានភាពអប់រំ, ២០២០)។

## ២.១១.តម្រូវការគ្រូបង្រៀនកម្រិតឧត្តមសម្រាប់ឆ្នាំសិក្សា២០១៩-២០២០

សម្រាប់ឆ្នាំសិក្សា២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវការជ្រើសគ្រូបង្រៀនកម្រិតឧត្តមចំនួន១០០០នាក់ ដើម្បីបំពេញតម្រូវការតាមវិទ្យាល័យនានានៅទូទាំងប្រទេស (៣១៣០.បល, ២០១៩)។ ក្នុងការជ្រើសរើសនោះខេត្តកណ្ដាលត្រូវការជ្រើសរើសចំនួន ៥៥ នាក់មាន១៣មុខវិជ្ជារួមមាន អក្សរសាស្ត្រខ្មែរ ៣នាក់ អង់គ្លេស ៣នាក់ សីលធម៌-ពលរដ្ឋវិជ្ជា ២នាក់ ប្រវត្តិវិទ្យា ៤នាក់ ភូមិវិទ្យា ៤នាក់ គីមីវិទ្យា ៧នាក់ ជីវវិទ្យា ៤នាក់ ផែនដីវិទ្យា ៥នាក់ រូបវិទ្យា ៤នាក់ គណិតវិទ្យា ១០នាក់ ព័ត៌មានវិទ្យា ៦នាក់ អេឡិចត្រូនិច ១នាក់ និងមេកានិច ២នាក់ (តារាងបែងចែកក្របខ័ណ្ឌប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម, ២០១៩)។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ការប្រមូលទិន្នន័យ

ក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ ដើម្បីប្រមូលព័ត៌មានដែលទាក់ទងនឹងប្រធានបទនេះ។ ឧបករណ៍ក្នុងការប្រមូលយកទិន្នន័យគឺកម្រងសំណួរដែលបានចែកជាបីប្រភេទគឺ កម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត កម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងកម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងវិទ្យាល័យ។ កម្រងសំណួរទាំងបីប្រភេទដែលអ្នកសិក្សាស្រាវជ្រាវបង្កើតឡើងខាងលើគឺតាមរយៈការណែនាំ ការអាន ការពិនិត្យទៅលើឯកសារផ្សេងៗដែលពាក់ព័ន្ធ។

## ៣.២.ទីតាំងនៃការស្រាវជ្រាវ

ដើម្បីឱ្យឆ្លើយតបទៅនឹងប្រធានបទក្នុងការស្រាវជ្រាវខាងលើ អ្នកសិក្សាបានសម្រេចជ្រើសរើសមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ទាំង១១ នៅក្នុងខេត្តកណ្តាល និងវិទ្យាល័យចំនួន១១ ដែលស្ថិតនៅក្នុងស្រុកទាំង១១ (មួយស្រុកជ្រើសរើសយកមួយ) នៃខេត្តកណ្តាល សម្រាប់យកមកធ្វើការសិក្សាស្រាវជ្រាវ។ វិទ្យាល័យទាំង១១ នោះរួមមាន វិទ្យាល័យព្រែកស្លែងក្នុងស្រុកកណ្តាលស្ទឹង វិទ្យាល័យជ័យវរ្ម័នទី៧ ក្នុងស្រុកកៀនស្វាយ វិទ្យាល័យព្រែកលួងក្នុងស្រុកខ្សាច់កណ្តាល វិទ្យាល័យបន ហស ព្រែកតាឡុងក្នុងស្រុកកោះធំ វិទ្យាល័យសហ កំពង់ភ្នំក្នុងស្រុកលើកដែក វិទ្យាល័យពាមឧកញ៉ាអុងក្នុងស្រុកល្វាឯម វិទ្យាល័យជា ស៊ីម ព្រែកអញ្ចាញក្នុងស្រុកមុខកំពូល វិទ្យាល័យថ្នល់ទទឹងក្នុងស្រុកអង្គស្នួល វិទ្យាល័យហ៊ុន សែន កោះចិនក្នុងស្រុកពញាឮ វិទ្យាល័យហ៊ុន សែន ស្អាងក្នុងស្រុកស្អាង និងវិទ្យាល័យសិត្បូក្នុងក្រុងតាខ្មៅ ។ មូលហេតុនៃការជ្រើសបែបនេះពីព្រោះ មន្ទីរអប់រំ យុវជន និងកីឡាជាកន្លែកដែលផ្ទុកទិន្នន័យចំនួនវិទ្យាល័យ និងចំនួនគ្រូបង្រៀនទាំងអស់ពិសេសគឺព័ត៌មានដែលទាក់ទងនឹងគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យទាំងនោះ។

ចំណែកឯការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គឺជាកន្លែងដែលផ្ទុកព័ត៌មានចំនួនវិទ្យាល័យ និងគ្រូបង្រៀនក្នុងស្រុក ។ រីឯការជ្រើសយកវិទ្យាល័យមួយក្នុងមួយស្រុក គឺដោយសារចង់បានព័ត៌មានបន្ថែមទៀតនៅវិទ្យាល័យទាំងនោះផ្ទាល់ ។

## ៣.៣.ការជ្រើសរើសភាគសំណាក

ដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសភាគសំណាកនៃអ្នកចូលរួមចំនួន២៣រូប ដោយ១រូប នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាលគឺថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល ១១រូប ជាថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ទាំង១១ និង១១រូបទៀត គឺគណៈគ្រប់គ្រងវិទ្យាល័យទាំង១១ ដែលជ្រើសចេញពីស្រុកទាំង ១១។ ចំពោះមូលហេតុនៃការជ្រើសរើសភាគសំណាកបែបនេះ ពីព្រោះពួកគាត់ទាំងនោះជាអ្នកដែលធ្វើការងារពាក់ព័ន្ធផ្ទាល់ជាមួយនឹងការចាត់ចែងគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ។

## ៣.៤.ឧបករណ៍ក្នុងការស្រាវជ្រាវ

ក្នុងការប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានបង្កើតជាកម្រងសំណួរស្រាវជ្រាវចំនួនបីប្រភេទគឺ ប្រភេទទី១ ជាកម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ប្រភេទទី២ ជាកម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និង ប្រភេទទី៣ ជាកម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងវិទ្យាល័យ។

កម្រងសំណួរប្រភេទទី១ ជាកម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាដែលមានពីរផ្នែក។ ផ្នែកទី១ គឺជាសំណួរទម្រង់បិទ និយាយអំពីព័ត៌មានផ្ទាល់ខ្លួន និងស្ថិតិវិទ្យាល័យ និងគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្ត ដែលក្នុងនោះមាន ភេទ អាយុ ចំនួនវិទ្យាល័យ និងចំនួនគ្រូបង្រៀនកម្រិតឧត្តមនៅក្នុងខេត្ត ចំនួនវិទ្យាល័យដែលខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម និងតំបន់ដែលវិទ្យាល័យទាំងនោះស្ថិតនៅ។ ផ្នែកទី២ ជាសំណួរទម្រង់បើក និយាយអំពីមតិយោបល់ដែលតម្រូវឱ្យថ្នាក់ដឹកនាំមន្ទីរបញ្ចេញមតិយោបល់ទាក់ទងទងនឹងមូលហេតុដែលនាំឱ្យខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម

នៅក្នុងខេត្ត បញ្ហាប្រឈមនៅក្នុងខេត្តដែលបណ្តាលមកពីបញ្ហាខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម វិធានការដោះស្រាយបញ្ហាខ្វះ និងលើសគ្រូបង្រៀន ព្រមទាំងមតិយោបល់ និងសំណូមពរទាក់ទងនឹងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ន។

កម្រងសំណួរប្រភេទទី២ ជាកម្រងសំណួរសម្រាប់សម្ភាសន៍ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌដែលមានពីរផ្នែក។ ផ្នែកទី១ គឺជាសំណួរទម្រង់បិទ និយាយអំពីព័ត៌មានផ្ទាល់ខ្លួន និងស្ថិតិវិទ្យាល័យ និងគ្រូបង្រៀនកម្រិតឧត្តមក្នុងស្រុក ដែលក្នុងនោះមាន ភេទ អាយុ ឈ្មោះស្រុក ចំនួនវិទ្យាល័យ និងចំនួនគ្រូបង្រៀនកម្រិតឧត្តមនៅក្នុងស្រុក ចំនួន និងឈ្មោះវិទ្យាល័យដែលខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម និងតំបន់ដែលវិទ្យាល័យទាំងនោះស្ថិតនៅ។ ផ្នែកទី២ ជាសំណួរទម្រង់បើក និយាយអំពីមតិយោបល់ ដែលតម្រូវឱ្យប្រធាន ឬអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បញ្ចេញមតិយោបល់ទាក់ទងទងនឹងមូលហេតុដែលនាំឱ្យខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តមនៅក្នុងក្រុង ស្រុក ខណ្ឌ បញ្ហាប្រឈមនៅក្នុងក្រុង ស្រុក ខណ្ឌ ដែលបណ្តាលមកពីបញ្ហាខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម វិធានការដោះស្រាយបញ្ហាខ្វះ និងលើសគ្រូបង្រៀន ព្រមទាំងមតិយោបល់ និងសំណូមពរ ទាក់ទងនឹងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ន។

កម្រងសំណួរប្រភេទទី៣ ជាកម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងវិទ្យាល័យ ដែលមានពីរផ្នែក។ ផ្នែកទី១ គឺជាសំណួរទម្រង់បិទ និយាយអំពីព័ត៌មានផ្ទាល់ខ្លួន និងស្ថិតិគ្រូបង្រៀនកម្រិតឧត្តមក្នុងវិទ្យាល័យ ដែលក្នុងនោះមានភេទ អាយុ ឈ្មោះវិទ្យាល័យ ចំនួនគ្រូបង្រៀនកម្រិតឧត្តមក្នុងវិទ្យាល័យ ចំនួនគ្រូបង្រៀនកម្រិតឧត្តមដែលខ្វះ ឬលើសក្នុងវិទ្យាល័យ និងតំបន់ដែលវិទ្យាល័យតាំងនៅ។ ផ្នែកទី២ ជាសំណួរទម្រង់បើក និយាយអំពីមតិយោបល់របស់គណៈគ្រប់គ្រងវិទ្យាល័យ ដែលតម្រូវឱ្យគណៈគ្រប់គ្រងវិទ្យាល័យបញ្ចេញមតិយោបល់ទាក់ទងទងនឹងមូលហេតុដែលនាំឱ្យខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តមនៅក្នុងវិទ្យាល័យ បញ្ហាប្រឈមនៅក្នុងសាលារៀន ដែលបណ្តាលមកពីបញ្ហាខ្វះ និងលើសគ្រូ

បង្រៀនកម្រិតឧត្តម វិធានការដោះស្រាយបញ្ហាខ្វះ និងលើសគ្រូបង្រៀន ព្រមទាំងមតិយោបល់ និងសំណូមពរ ទាក់ទងនឹងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ន។

## ៣.៥.ដំណាក់កាលនៃការប្រមូលទិន្នន័យ

បន្ទាប់ពីទទួលបានការឯកភាពពីសាស្ត្រាចារ្យដឹកនាំបង្គោល និងដឹកនាំរងទៅលើកម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ និងទទួលបានលិខិតអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតអនុញ្ញាតរបស់វិទ្យាស្ថានជាតិអប់រំទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាលដើម្បីសុំការសហការក្នុងការប្រមូលទិន្នន័យនៅតាមគោលដៅដែលបានកំណត់។ អ្នកសិក្សាស្រាវជ្រាវបានសុំការអនុញ្ញាតពីថ្នាក់ដឹកនាំមន្ទីរ ដើម្បីឱ្យជួយបំពេញកម្រងសំណួរដែលបានរៀបចំទុករួចជាស្រេចដែលមានទម្រង់ជា Google Form តាមប្រព័ន្ធអនឡាញដែលអ្នកសិក្សាស្រាវជាវបានផ្ញើតាមតេឡេក្រាម និងសម្ភាសន៍ផ្ទាល់បន្ថែមទៀត និងបានស្នើសុំឱ្យមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាលធ្វើចំណារដើម្បីជូនដំណឹងដល់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យគោលដៅ ព្រមទាំងសុំលេខទូរសព្ទរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យគោលដៅទាំងនោះ ដើម្បីឱ្យអ្នកសិក្សាស្រាវជ្រាវអាចទាក់ទងទៅអ្នកដែលពាក់ព័ន្ធឱ្យជួយសហការ។ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតដែលមានចំណារពីមន្ទីរអប់រំ យុវជន និងកីឡាទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកដើម្បីជួយសហការ និងជូនដំណឹងបន្តដល់វិទ្យាល័យគោលដៅ។ ដោយឡែកការិយាល័យអប់រំ ក្រុង ស្រុក និងវិទ្យាល័យមួយចំនួនដែលនៅឆ្ងាយ អ្នកសិក្សាស្រាវជ្រាវបានទាក់ទងនឹងតាមទូរសព្ទដើម្បីសុំការអនុញ្ញាតផ្ញើលិខិតដែលមានចំណារពីមន្ទីរអប់រំ យុវជន និងកីឡាតាមតេឡេក្រាម។ ក្រោយពីបានធ្វើទំនាក់ទំនងជាមួយការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងវិទ្យាល័យគោលដៅរួចរាល់ អ្នកសិក្សាស្រាវជ្រាវបានផ្ញើកម្រងសំណួរដែលមានទម្រង់ជា Google Form ទៅកាន់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យគោលដៅដែលនៅឆ្ងាយមួយចំនួនដើម្បីបំពេញតាមតេឡេក្រាម និងបានធ្វើការសម្ភាសន៍ផ្ទាល់ជាមួយនឹងថ្នាក់

ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យគោលដៅមួយចំនួនទៀត។

## ៣.៦.ការវិភាគទិន្នន័យ

ក្នុងការវិភាគទិន្នន័យ ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីបកស្រាយពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យនានានៅក្នុងខេត្តកណ្តាល។ ទិន្នន័យដែលទទួលបានតាមរយៈកម្រងសំណួរ អ្នកស្រាវជ្រាវនឹងបកស្រាយទិន្នន័យទាំងនោះទៅតាមផ្នែកនីមួយនៃកម្រងសំណួរតាមបែបគុណវិស័យដែលរៀបរាប់អំពីចំនួនវិទ្យាល័យដែលខ្វះ និងលើសគ្រូ ចំនួនគ្រូដែលខ្វះ និងលើស មូលហេតុ បញ្ហាប្រឈម ផលប៉ះពាល់ ដំណោះស្រាយ អំពីបញ្ហាលើស ខ្វះគ្រូបង្រៀនកម្រិតឧត្តម ដើម្បីឱ្យការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យក្នុងខេត្តកណ្តាលកាន់តែមានភាពឆ្លើយតបទៅនឹងតម្រូការ។ ព្រមជាមួយគ្នានេះដែរ អ្នកសិក្សាស្រាវជ្រាវ បានលើកជាសំណូមពរនូវចំណុចខ្វះខាតដើម្បីកែលម្អចំណុចខ្វះខាតទាំងនោះឱ្យកាន់តែល្អប្រសើរ។

## ៣.៧.ក្រមសីលធម៌នៃការស្រាវជ្រាវ

ការយកចិត្តទុកដាក់ទៅលើក្រមសីលធម៌នៃការស្រាវជ្រាវ គឺជាកត្តាដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវ ដើម្បីបង្កើននូវភាពទុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ។ មួយវិញទៀតទិន្នន័យដែលទទួលបាន ហើយយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះមានភាពត្រឹមត្រូវមិនលម្អៀង។ អ្នកសិក្សាស្រាវជ្រាវបានរក្សាក្រមសីលធម៌ខ្ពស់គ្រប់ដំណាក់កាលនីមួយៗមុនពេលស្រាវជ្រាវ។ អ្នកសិក្សាស្រាវជ្រាវបានសុំការអនុញ្ញាតពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តឱ្យជួយសហការ និងផ្តល់ដំណឹងដល់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក និងគណៈគ្រប់គ្រងសាលារៀនដើម្បីឱ្យពួកគាត់ជួយសហការក្នុងអំឡុងពេលស្រាវជ្រាវ។ មុនការបំពេញកម្រងសំណួរ អ្នកសិក្សាស្រាវបានជម្រាបដល់អ្នកចូលរួមផ្តល់ចម្លើយពីគោលបំណង និងសារប្រយោជន៍នៃការសិក្សាស្រាវជ្រាវឱ្យបានជ្រាប និងចូលរួមផ្តល់ចម្លើយដែលអាចទុកចិត្តបាន។ អ្នកសិក្សាស្រាវជ្រាវរក្សាសិទ្ធិ និងកិត្តិយសជានិច្ច

ចំពោះអ្នកចូលរួម។ បន្ទាប់ពីទទួលបានទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ បានរក្សាភាពស្មោះត្រង់ចំពោះការបញ្ចូលទិន្នន័យដែលជាចម្លើយរបស់អ្នកចូលរួម ដោយមិនបំផ្លើស និងបំពេញបន្ថែមលើចំណុចណាមួយឡើយ។ ការធ្វើដូច្នេះបង្ហាញថា ការសិក្សាស្រាវជ្រាវនេះនឹងទទួលបានលទ្ធផលល្អ និងជឿទុកចិត្តបាន ហើយវាក៏ជាភស្តុតាងមួយបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវ និងក្រមសីលធម៌ខ្ពស់ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវមួយរូប។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

## ៤.១.អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ

ក្រោយពេលបូកសរុបទិន្នន័យ ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយសំណួរសម្ភាសន៍រួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមផ្តល់ព័ត៌មាន សរុបមានចំនួន ២៣នាក់ ស្រី ១នាក់ ដែលក្នុងនោះ មានថ្នាក់ដឹកនាំមន្ទីរ ០១នាក់ ថ្នាក់ដឹកនាំក្រុង/ស្រុក ១១នាក់ និងគណៈគ្រប់គ្រងវិទ្យាល័យ ១១នាក់។

តារាង៤.១. ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល | ០១នាក់ | ០០នាក់ | ០១នាក់ |
| ថ្នាក់ដឹកនាំការិយាល័យអយក ក្រុង/ស្រុក | ១០នាក់ | ០១នាក់ | ១១នាក់ |
| គណៈគ្រប់គ្រងវិទ្យាល័យ | ១១នាក់ | ០០នាក់ | ១១នាក់ |
| សរុប | ២២នាក់ | ០១នាក់ | ២៣នាក់ |

## ៤.២.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំមន្ទីរអប់រំ

ក្រោយពីបានធ្វើការសម្ភាសរួចរាល់ ទិន្នន័យដែលទទួលបានបង្ហាញថា ក្នុងឆ្នាំសិក្សា ២០១៩-២០២០ ខេត្តកណ្តាលមានវិទ្យាល័យទាំងអស់ចំនួន៣៩វិទ្យាល័យ ដែលក្នុងនោះវិទ្យាល័យដែលស្ថិតនៅក្នុងតំបន់ជនបទមានចំនួន២៨ ចំណែកវិទ្យាល័យដែលស្ថិតនៅតំបន់ទីប្រជុំជនមានចំនួន១១វិទ្យាល័យ។ ចំណែកឯគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅវិទ្យាល័យមានចំនួន ១៤៨៨នាក់ ស្រី ៥១៦នាក់។

ក្នុងខេត្តកណ្តាលទាំងមូលមានវិទ្យាល័យចំនួន២៩ ដែលមានតម្រូវការ(ខ្វះ) គ្រូបង្រៀនកម្រិតឧត្តម និងមានវិទ្យាល័យចំនួន១០ ដែលមិនមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តម ។ ប៉ុន្តែក្នុងចំណោមវិទ្យាល័យទាំង២៩ ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមនោះ ក៏មានវិទ្យាល័យមួយចំនួនលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាមួយចំនួនផងដែរ ហើយវិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមភាគច្រើនគឺស្ថិតនៅតំបន់ជនបទ រីឯវិទ្យាល័យដែលលើសគ្រូតាមមុខវិជ្ជាភាគច្រើនមានទីតាំងនៅតំបន់ទីប្រជុំជន។

ចំពោះការបែងចែកគ្រូបង្រៀនកម្រិតឧត្តមចេញថ្មី កន្លងមកមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាលបានបង្កើតជាគណៈកម្មការជ្រើសប៉ុស្តិ៍បម្រើការងារ ដែលមានប្រធានមន្ទីរជាប្រធានគណៈកម្មការនេះ សម្រាប់ធ្វើការជ្រើសរើសវិទ្យាល័យណាដែលមានការខ្វះខាតគ្រូបង្រៀនកម្រិតឧត្តមខ្លាំងជាងគេ មុននឹងបញ្ជូនគ្រូបង្រៀនកម្រិតឧត្តមចេញថ្មីទៅ។

តារាង៤.២. ស្ថិតិវិទ្យាល័យ និងចំនួនគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តកណ្តាល

| ល.រ | ឈ្មោះ ក្រុង/ស្រុក | ចំនួនវិទ្យាល័យ | ចំនួនគ្រូបង្រៀនកម្រិតឧត្តម | តំបន់ទីប្រជុំជន | តំបន់ជនបទ |
|---|---|---|---|---|---|
| ១ | កណ្តាលស្ទឹង | ៣ | ១២៤/៥៧ | ០ | ៣ |
| ២ | កៀនស្វាយ | ៣ | ៨៥/៣៩ | ០ | ៣ |
| ៣ | ខ្សាច់កណ្តាល | ៤ | ១៨២/៥៨ | ០ | ៤ |
| ៤ | កោះធំ | ៤ | ១០៩/៣៦ | ០ | ៤ |
| ៥ | លើកដែក | ២ | ៦៣/២១ | ០ | ២ |
| ៦ | ល្វាឯម | ៣ | ៦៦/១៦ | ០ | ៣ |
| ៧ | មុខកំពូល | ២ | ១៣១/៣៧ | ២ | ០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | អង្គស្នួល | ៥ | ១៨៩/៦១ | ៥ | ០ |
| ៩ | ពញាឮ | ៥ | ១៥១/៤៧ | ០ | ៥ |
| ១០ | ស្អាង | ៤ | ១១៦/៤៥ | ០ | ៤ |
| ១១ | តាខ្មៅ | ៤ | ២៧២/៩៩ | ៤ | ០ |
| សរុប | | ៣៩ | ១៤៨៨/៥១៦ | ១១ | ២៨ |

### ៤.២.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យ

តាមការផ្តល់ចម្លើយរបស់ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល មូលហេតុដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យនានាក្នុងខេត្តកណ្តាល គឺបណ្តាលមកពីទីតាំងវិទ្យាល័យដែលខ្វះគ្រូនោះនៅឆ្ងាយពីទីប្រជុំជន ហើយធនធានមនុស្សដែលជាគ្រូបង្រៀននៅតំបន់នោះមានតិចតួចពេក។ មួយវិញទៀត មូលហេតុដែលនាំឱ្យខ្វះគ្រូគឺដោយសារវិទ្យាល័យទាំងនោះទើបតែបង្កើតថ្មីដែលនាំឱ្យមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមច្រើន ផ្គត់ផ្គង់មិនទាន់គ្រប់។ ជាមួយគ្នានេះដែរ ការផ្តល់ ការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡាកន្លងមកគឺមិនគ្រាប់គ្រាន់តាមឯកទេសតាមតម្រូវការសាលា និងខុសតម្រូវការ។ ម្យ៉ាងវិញទៀត នៅតាមវិទ្យាល័យមួយចំនួន ក្នុងរយៈពេលចុងក្រោយនេះ ចំនួនសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិមានការកើនឡើងយ៉ាងគំហុក។ នេះក៏ជាមូលហេតុដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតឧត្តមផងដែរ។ មានមូលហេតុមួយទៀតដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតផងដែរនោះ គឺការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការបែងចែកវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ត្រង់ចំណុចនេះ ថ្នាក់ដឹកនាំមន្ទីរបានបញ្ជាក់បន្ថែមថា ដោយសារការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការបែងចែកបែបនេះ ធ្វើឱ្យវិទ្យាល័យដែលមានសិស្សជ្រើសរើសយកវិទ្យាសាស្ត្រសង្គមច្រើន ហើយមានគ្រូបង្រៀនកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រសង្គមតិចនាំឱ្យវិទ្យាល័យ

នោះខ្វះគ្រូបង្រៀនកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រសង្គម( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល)។

### ៤.២.២.មូលហេតុលើសតាមមុខវិជ្ជា

ថ្នាក់ដឹកនាំមន្ទីរបានលើកយកមូលហេតុពីរយ៉ាង ដែលនាំឱ្យមានបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ។ ទី១ គឺការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការបែងចែក ផ្នែកវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម ដែលធ្វើឱ្យវិទ្យាល័យដែលសិស្សជ្រើសរើសផ្នែកវិទ្យាសាស្ត្រពិតតិច ហើយមានគ្រូមុខវិជ្ជាវិទ្យាសាស្ត្រច្រើន នាំឱ្យវិទ្យាល័យនោះលើសគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ មូលហេតុទី២ គឺការថយចុះចំនួនសិស្សនៅវិទ្យាល័យមួយចំនួនដោយសារការផ្លាស់ប្ដូរទីលំនៅរបស់សិស្សតាមអាណាព្យាបាល ដែលតម្រូវឱ្យសិស្សត្រូវផ្លាស់ចេញពីវិទ្យាល័យដែលខ្លួនធ្លាប់រៀនទៅវិទ្យាល័យដែលនៅជិតទីលំនៅថ្មី( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល)។

### ៤.២.៣.បញ្ហាប្រឈមចំពោះដោយសារបញ្ហាខ្វះគ្រូបង្រៀនកម្រិតឧត្តម

បញ្ហាប្រឈមនៅពេលខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ថ្នាក់ដឹកនាំមន្ទបានផ្ដល់ចម្លើយយ៉ាងខ្លីថា វិទ្យាល័យជាអ្នកជួបបញ្ហាប្រឈមខ្លួនឯងផ្ទាល់( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល)។

### ៤.២.៤.បញ្ហាប្រឈមចំពោះបញ្ហាលើសគ្រូបង្រៀនតាមមុខវិជ្ជា

តាមការផ្ដល់ចម្លើយរបស់ថ្នាក់ដឹកនាំមន្ទីរ បញ្ហាប្រឈមការលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជានៅវិទ្យាល័យ គឺគ្រូបង្រៀនកម្រិតឧត្តមបង្រៀនមិនគ្រប់និយាមម៉ោងបង្រៀន( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល)។

### ៤.២.៥.វិធានដោះស្រាយបញ្ហាប្រឈមដោយសារខ្វះគ្រូបង្រៀនកម្រិតឧត្តម

វិធានការដោះស្រាយបញ្ហាខាងលើ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាបុគ្គលិកក្នុងសាលារៀននីមួយៗ ដែលមាននាយកសាលាជាប្រធាន( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល )។

### ៤.២.៦.វិធានដោះស្រាយបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជា

ចំពោះបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជា មន្ទីរអប់រំ យុវជន និងកីឡាខេត្តមានវិធានការមួយចំនួនដូចជា ណែនាំឱ្យវិទ្យាល័យដែលលើសនោះអនុវត្តន៍គោលការណ៍ពង្រាយគ្រូបង្រៀនពីសាលាលើសទៅសាលាដែលខ្វះ អនុញ្ញាតឱ្យវិទ្យាល័យដែលខ្វះ ខ្ចីគ្រូបង្រៀនពីវិទ្យាល័យលើសគ្រូបង្រៀនទៅជួយ ដោយគិតជាប្រាក់ម៉ោងបន្ថែមពីខាងក្រសួងអប់រំ យុវជន និងកីឡា។ ដំណោះស្រាយមួយទៀតគឺ មន្ទីរមិនបញ្ជូនគ្រូចេញថ្មីទៅវិទ្យាល័យដែលមានគ្រូគ្រាប់គ្រាន់ទៀតនោះទេ ( ទិន្នន័យគុណវិស័យទទួលបានពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល )។

## ៤.៣.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំការិយាល័យអយក ក្រុង/ស្រុក

ក្រាប ១ ភេទរបស់ថ្នាក់ដឹកនាំការិយាល័យអយក ក្រុងស្រុកដែលបានចូលរួមផ្ដល់បទសម្ភាសន៍



តាមក្រាប១ បង្ហាញថា ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដែលចូលរួមផ្តល់បទសម្ភាស៍ មានចំនួន១១នាក់ ក្នុងនោះថ្នាក់ដឹកនាំភេទប្រុសមាន១០ នាក់ ស្មើនឹង៩០.៩% ហើយភេទស្រីមាន១នាក់ ស្មើនឹង៩.១%។ តាមទិន្នន័យនេះបង្ហាញថាអ្នកចូលរួមផ្តល់ចម្លើយភាគច្រើនមានភេទប្រុស។

**ក្រាប២ អាយុរបស់ថ្នាក់ដឹកនាំការិយាល័យអយក ក្រុង/ស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍**




តាមក្រាប២ បង្ហាញថាថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដែលចូលរួមផ្តល់បទសម្ភាស៍ មានចំនួន១១នាក់ ដែលក្នុងនោះអាយុចន្លោះពី៣០ឆ្នាំ ទៅ ៤០ឆ្នាំ មាន១ នាក់ ស្មើនឹង ៩.០៩% អាយុចន្លោះពី៤០ឆ្នាំ ទៅ ៥០ឆ្នាំមាន៣នាក់ស្មើនឹង ២៧.២៧% អាយុចន្លោះពី ៥០ឆ្នាំ ទៅ ៦០ឆ្នាំមាន ៧នាក់ ស្មើនឹង៦៣.៦៤%។ តាមទិន្នន័យនេះបង្ហាញថា ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដែលចូលរួមផ្តល់ចម្លើយភាគច្រើនមានអាយុចន្លោះពី៥០ឆ្នាំ ទៅ៦០ឆ្នាំ។

**ក្រាប៣ តួនាទីរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍**




តាមក្រាប៣ បង្ហាញថាថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដែលចូលរួមផ្តល់បទសម្ភាសន៍មានចំនួន១១នាក់ ក្នុងនោះតួនាទីជាប្រធានការិយាល័យមានចំនួន៤នាក់ ស្មើនឹង ៣៦.៣៦% តួនាទីជាអនុប្រធានមាន៦នាក់ ស្មើនឹង ៥៤.៥៥% និងតួនាទីជាមន្ត្រីការិយាល័យមាន១នាក់ ស្មើនឹង៩.០៩%។ ទិន្នន័យនេះបង្ហាញថា ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដែលបានចូលរួមផ្តល់បទសម្ភាសន៍ភាគច្រើនមានតួនាទីជាអនុប្រធានការិយាល័យ។

តារាង ៤.៣.វិទ្យាល័យដែលមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមនៅតាមក្រុង/ស្រុកទាំង១១

| ល.រ | ឈ្មោះស្រុក | ឈ្មោះវិទ្យាល័យ | តម្រូវការគ្រូឧត្តម( ខ្ន: ) | លើសតម្រូវការ |
|---|---|---|---|---|
| ១ | កណ្តាលស្ទឹង | បនហសដើមឫស្ស | ៨ | |
| | | ព្រែកស្លែង | ២ | |

| | | | | |
|---|---|---|---|---|
| | | ហស.កំពង់កន្ទួត | ០ | ៩ |
| ២ | កៀនស្វាយ | ជ័យវរ្ម័នទី៧ | ១២ | |
| | | ហស.សិរីជីដុះ | ០ | |
| | | សាន់នីវូសំពោងធំ | ៥ | |
| ៣. | ខ្សាច់កណ្តាល | ហសខ្សាច់កណ្តាល | ៩ | |
| | | ព្រែកលួង | ២ | |
| | | ហស.រ៉ូតាខ្សាច់កណ្តាល | ១០ | |
| | | ហស.បានដារ | ១០ | |
| ៤ | កោះធំ | ហសកោះធំ | ៣ | |
| | | បន.ហស.ព្រែកតាឌួង | ៤ | |
| | | ហស.កំពង់កុង | ៥ | |
| | | ហស.សំពៅពូន | ៥ | |
| ៥ | លើកដែក | ហស.កំពង់ភ្នំ | ៦ | |
| | | បន.ហស.ពាមរាំង | ១០ | |
| ៦ | ល្វាឯម | ទឹកឃ្លាំង | ៦ | |
| | | ហស.ពាមឧកញ៉ាអុង | ៤ | |

| | | | | |
|---|---|---|---|---|
| | | ហស.ល្វាស | ០ | |
| ៧ | មុខកំពូល | ជា ស៊ីមព្រែកអញ្ចាញ | ០ | |
| | | សិរីមង្គល | ០ | |
| ៨ | អង្គស្នួល | ហស.អង្គស្នួល | ៧ | |
| | | ហស.ថ្នល់ទទឹង | ៥ | |
| | | ហស.ត្រពាំងត្នោត | ១០ | |
| | | ហស.អង្គពពាយ | ៥ | |
| | | សម្តេចព្រះមហាសង្ឃរាជ ប៊ូគ្រី | ២០ | |
| ៩ | ពញាឮ | ទេពប្រណម្យ | ០ | |
| | | ហស.ព្រះធម្មស្រះ | ៦ | |
| | | ហស.កោះចិន | ១ | |
| | | ហស.អូរកុង | ០ | |
| | | អគ.ហស.ព្រែកតាទែន | ៨ | |
| ១០ | ស្អាង | ហស.ស្អាង | ១១ | |
| | | ហស.ក្រាំងយ៉ូវ | ៤ | |

| | | | | |
|---|---|---|---|---|
| | | ត្រើយស្លា | ១២ | |
| | | ហស.ព្រៃកអំបិល | ៧ | |
| ១១ | តាខ្មៅ | ហស.សេរីភាព | ០ | |
| | | ហស.តាខ្មៅ | ០ | |
| | | វត្តខ្សាន់ឈូងលាក | ០ | |
| | | សិត្បូ | ១១ | |
| សរុប | | ៣៩ | ២០៨ | ៩ |

តាមតារាង៤.៣ បង្ហាញថា ក្នុងចំណោមក្រុង/ស្រុកទាំង ១១ មានតែស្រុក១ ប៉ុណ្ណោះ ដែលវិទ្យាល័យក្នុងស្រុកនេះពុំមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តម គឺស្រុកមុខកំពូល។ ហើយក្នុងចំណោមវិទ្យាល័យទាំង៣៩ នៅក្នុងខេត្តកណ្តាល មានវិទ្យាល័យចំនួន២៩ ដែលមានត្រូវការគ្រូបង្រៀនកម្រិតឧត្តម និងមានវិទ្យាល័យមួយតែមួយប៉ុណ្ណោះ ដែលមានគ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការ គឺវិទ្យាល័យហ៊ុន សែនកំពង់កន្ទួតដែលមានគ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការចំនួន៩នាក់។ សរុបតម្រូវការគ្រូបង្រៀនកម្រិតឧត្តមសរុបនៅទូទាំងខេត្តមានចំនួន២០៨នាក់។ ទិន្នន័យនេះបង្ហាញថាខេត្តកណ្តាលនៅមានការខ្វះខាតគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅវិទ្យាល័យមួយចំនួនទៀត។ ក៏ប៉ុន្តែក្នុងចំណោមវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តមខាងលើ ក៏មានវិទ្យាល័យខ្លះលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាខ្លះផងដែរ បើតាមការផ្តល់ចម្លើយរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក មួយចំនួន។

ក្រាប៤ តំបន់ដែលវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តមស្ថិតនៅ នៅក្នុងក្រុងស្រុកទាំង១០




តាមក្រាប៤ បង្ហាញថាក្នុងចំណោមក្រុង/ស្រុកទាំង១០ដែលមានវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តម មានស្រុកចំនួន៨ មានវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តមស្ថិតនៅតំបន់ជនបទ ដែលស្មើនឹង ៨០% និងក្រុង/ស្រុកចំនួន២ ដែលមានវិទ្យាល័យខ្វះគ្រូបង្រៀនកម្រិតឧត្តមស្ថិតនៅតំបន់ទីប្រជុំជន ស្មើនឹង២០%។ ទិន្នន័យនេះបង្ហាញថា វិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមភាគច្រើន ស្ថិតនៅតំបន់ជនបទ។

ចំពោះវិទ្យាល័យមួយ ដែលមានគ្រូបង្រៀនកម្រិតលើសតម្រូវការនោះគឺមានទីតាំងស្ថិតនៅតំបន់ជនបទផងដែរ។ ដោយឡែកវិទ្យាល័យខ្លះដែលមានគ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការតាមមុខវិជ្ជាខ្លះ គឺវិទ្យាល័យខ្លះមានទីតាំងស្ថិតនៅតំបន់ទីប្រជុំជន និងវិទ្យាល័យខ្លះទៀតស្ថិតនៅតំបន់ជនបទ។ នេះបើតាមការសម្ភាសន៍ជាមួយថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកមួយចំនួន។

### ក្រាប៥ វិធានការក្នុងការចាត់តាំងបន្តគ្រូចេញថ្មីរបស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក




តាមក្រាប៥ បង្ហាញថាវិធានការក្នុងការចាត់តាំងបន្តគ្រូចេញថ្មី ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុកទាំង១១ អនុវត្តតាមចំណាត់ការរបស់មន្ទីរ។ ទិន្នន័យនេះបង្ហាញថា គ្រប់ការិយាល័យអយក ក្រុង/ស្រុកទាំងអស់ សុទ្ធតែអនុវត្តតាមចំណាត់ការរបស់មន្ទីរទៅលើការចាត់តាំងបន្តគ្រូបង្រៀនកម្រិតឧត្តមចេញថ្មី។

### ៤.៣.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យ

កង្វះខាតគ្រូបង្រៀនកម្រិតនៅតាមវិទ្យាល័យនានានៅតាមក្រុង/ស្រុកទាំង១០ គឺមានមូលហេតុផ្សេងៗគ្នាជាច្រើននៅតាមក្រុង/ស្រុកនីមួយៗ ប៉ុន្តែមានមូលហេតុមួយចំនួនគឺស្រុកខ្លះមានដូចគ្នា។ ដោយឡែកស្រុកមុខកំពូលគឺមិនមានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមឡើយ។ តាមលទ្ធផលសម្ភាសន៍ដែលទទួលបាន មូលហេតុដែលនាំឱ្យមានកង្វះខាតគ្រូបង្រៀនកម្រិតឧត្តមដែលថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំងនោះបានលើកឡើងមានដូចជា ការជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡារៀងរាល់ឆ្នាំមានចំនួនតិចពេក គ្រូបង្រៀនកម្រិតឧត្តមចេញថ្មីនៅមិនបានយូរ ច្រើនផ្លាស់ប្តូរទីកន្លែងបម្រើការងារ(ផ្លាស់ចេញ) ទៅកាន់ទីប្រជុំជន ឬទៅកាន់មូលដ្ឋានរស់នៅ

(ស្រុកកំណើត) របស់គាត់ ឬផ្លាស់ចេញតាមសហព័ទ្ធ ។ មូលហេតុមួយទៀតគឺ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកគ្មានសិទ្ធិចាត់ចែងគ្រូបង្រៀនកម្រិតឧត្តមក្នុងស្រុក។ វិទ្យាល័យទើបបង្កើតថ្មីក៏ជាមូលហេតុដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតឧត្តមផងដែរ។ ជាមួយគ្នានេះដែរកំណើនសិស្សនៅកម្រិតមធ្យមទុតិយភូមិក៏នាំឱ្យមានកង្វះគ្រូបង្រៀនកម្រិតឧត្តដែរ។

តាមរយៈទិន្នន័យដែលបានពីការសម្ភាស អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ក្នុងចំណោមមូលហេតុទាំងអស់ខាងលើ មូលហេតុដែលសំខាន់ជាងគេគឺ ការជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡារៀងរាល់ឆ្នាំមានចំនួនតិចពេក ពីព្រោះមូលនេះមានថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដល់ទៅ៧រូបបានលើកឡើងពីមូលហេតុនេះ។ ហើយមូលហេតុសំខាន់មួយទៀតដែលមានថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជននិងកីឡាក្រុង/ស្រុកចំនួន៦រូបបានលើកឡើងនោះគឺគ្រូបង្រៀនកម្រិតឧត្តមចេញថ្មីនៅមិនបានយូរ ច្រើនផ្លាស់ប្តូរទីកន្លែងបម្រើការងារ(ផ្លាស់ចេញ) ទៅកាន់ទីប្រជុំជន ឬទៅកាន់មូលដ្ឋានរស់នៅ(ស្រុកកំណើត) របស់គាត់ ឬផ្លាស់ចេញតាមសហព័ទ្ធ ។

### ៤.៣.២.មូលហេតុលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជានៅតាមវិទ្យាល័យ

បញ្ហាលើសគ្រូបង្រៀនកម្រិតមានតែនៅក្នុងស្រុកកណ្តាលស្ទឹងមួយប៉ុណ្ណោះ ដែលលើសដល់ទៅ៩នាក់នៅវិទ្យាល័យហស.កំពង់កន្ទួត។ ហើយមូលហេតុដែលលើសនោះគឺដោយសារគ្រូបង្រៀនភាគច្រើនចង់បម្រើការងារតែនៅសាលារៀនដែលមានសិស្សច្រើន និងនៅជិតទីផ្សារ ដែលធ្វើឱ្យគ្រូបង្រៀនទាំងនោះសុំផ្លាស់ចូលទៅសាលារៀនដែលពួកគាត់ចង់ទៅ។ ចំណែកឯមូលហេតុដែលនាំលើសតាមមុខវិជ្ជាខ្លះ គឺមានថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជននិងកីឡាក្រុង/ស្រុកចំនួនពីរប៉ុណ្ណោះដែលបានលើកឡើងអំពីបញ្ហានេះ។ ហើយមូលហេតុដែលនាំឱ្យលើសតាមមុខវិជ្ជាគឺការប្តូរចូលពីគ្រូក្រៅខេត្ត និងក្រៅស្រុក ឬប្តូរចូលតាមសហព័ទ្ធដើម្បីបានមកនៅជិតផ្ទះ។

### ៤.៣.៣.បញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តម

កង្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមក្រុង/ស្រុកនានាក្នុងខេត្តកណ្ដាលធ្វើឱ្យមានបញ្ហាប្រឈមមួយចំនួននៅក្នុងក្រុង/ស្រុកទាំងនោះ។ ដោយឡែកក្នុងស្រុកមុខកំពូលពុំមានបញ្ហាប្រឈមឡើយពីព្រោះពុំមានបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្តម។ យោងតាមលទ្ធផលនៃការសម្ភាសថ្នាក់ដឹកនាំការិយាល័យអប់រំយុវជននិងកីឡាក្រុង/ស្រុក បញ្ហាប្រឈមដែលក្រុង/ស្រុកទាំង១០ បានជួបប្រទះដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តមមានដូចជា គ្រូបង្រៀនខុសក្របខ័ណ្ឌ បង្រៀនខុសឯកទេស ការសិក្សារបស់សិស្សទទួលបានលទ្ធផលមិនសូវល្អ លំបាកក្នុងការរៀបចំសិស្សក្នុងថ្នាក់(រៀបសិស្សលើសនិយាម)នៅក្នុងវិទ្យាល័យដែលខ្វះគ្រូ គ្រូបង្រៀនមិនបានដិតដល់ព្រោះមានម៉ោងបង្រៀនច្រើន ដោយសារទីតាំងសាលានៅឆ្ងាយ និងចុងក្រោយគឺសិស្សបោះបង់ការសិក្សាជាដើម ។

តាមទិន្នន័យខាងលើបង្ហាញថាកង្វះគ្រូបង្រៀនកម្រិតឧត្តម បាននាំមកនូវបញ្ហាប្រឈមជាច្រើន។ ដោយឡែកតាមការសំយោគទិន្នន័យក្នុងកម្រងសំណួរឃើញថា ក្នុងចំណោមបញ្ហាប្រឈមខាងលើ បញ្ហាប្រឈមដែលសំខាន់ជាងគេគឺ គ្រូបង្រៀនខុសក្របខ័ណ្ឌ បង្រៀនខុសឯកទេស ដែលនាំឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលមិនសូវល្អ ពីព្រោះមានថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជននិងកីឡាក្រុង/ស្រុកចំនួន១០រូប សុទ្ធតែបានលើកឡើងថាជួបបញ្ហាប្រឈមនេះ។

### ៤.៣.៤.បញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជា

បញ្ហាប្រឈមដែលបណ្ដាលមកពីលើសគ្រូបង្រៀនកម្រិតឧត្តម គឺមាននៅតែក្នុងស្រុកកណ្ដាលស្ទឹងមួយតែប៉ុណ្ណោះ ព្រោះមានតែនៅស្រុកនេះទេ ដែលមានវិទ្យាល័យលើសគ្រូបង្រៀនកម្រិតឧត្តម។ បញ្ហាប្រឈមដែលកើតឡើងដោយសារលើសគ្រូបង្រៀនកម្រិតឧត្តមដែលថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាស្រុកកណ្ដាលស្ទឹងបានលើកឡើងតាមរយៈការសម្ភាសគឺ វិទ្យាល័យដែលមានគ្រូលើសតម្រូវការ ពិបាកក្នុងការចាត់ចែងម៉ោងបង្រៀន(គ្រូបង្រៀនតិចម៉ោង តិចជាង ១០ ម៉ោង ក្នុង១សប្ដាហ៍ ខុសនិយាមម៉ោងបង្រៀន) ហើយគ្រូដែលនៅសាលារៀនខ្វះគ្រូមានសតិអារម្មណ៍មិនល្អក្នុងការ

បំពេញការងារ ព្រោះមានម៉ោងបង្រៀនច្រើន។ ចំណែកបញ្ហាប្រឈមដែលបណ្ដាលមកពីលើសគ្រូកម្រិតឧត្ដមតាមមុខវិជ្ជាខ្លះគឺមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ ព្រោះស្រុកដែលមានគ្រូកម្រិតឧត្ដមលើសតាមមុខវិជ្ជា(អង្គស្នួល និង ស្អាង)មានវិធានការអាចដោះស្រាយបានចំពោះបញ្ហានេះ។

### ៤.៣.៥.វិធានការដោះស្រាយបញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្ដមនៅវិទ្យាល័យ

តាមពិតការដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្ដម ជាកិច្ចការរបស់វិទ្យាល័យដែលខ្វះគ្រូផ្ទាល់ជាអ្នករៀបចំ ប៉ុន្តែការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ក៏មានតួនាទីរួមចំណែកដោះស្រាយបញ្ហានេះដែរ ហើយកន្លងមកការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក បានរួមចំណែកដោះស្រាយបញ្ហានេះផងដែរ។

តាមទិន្នន័យដែលទទួលបានពីកម្រងសំណួរសម្ភាសន៍ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកបង្ហាញថា ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្ដមនៅវិទ្យាល័យ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកបានឯកភាពឱ្យវិទ្យាល័យដែលខ្វះគ្រូឧត្ដម យកគ្រូកម្រិតមូលដ្ឋានដែលមានសមត្ថភាពខ្ពស់ទៅជួយបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដាក់សំណើរទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត គាំទ្រឱ្យវិទ្យាល័យដែលខ្វះគ្រូឧត្ដមជួល ឬខ្ចីគ្រូពីវិទ្យាល័យផ្សេងមកជួយបង្រៀន ឱ្យវិទ្យាល័យដែលខ្វះគ្រូធ្វើបញ្ជីតម្រូវការគ្រូបង្រៀនឱ្យបានច្បាស់លាស់ យល់ស្របឱ្យវិទ្យាល័យដែលខ្វះគ្រូរៀបចំសេវាបង្រៀនមានម៉ោងបន្ថែមដោយគិតជាប្រាក់ម៉ោងបន្ថែម អនុវត្តការពង្រាយគ្រូតាមគោលការណ៍ស្ម័គ្រចិត្ត។

តាមរយៈការប្រមូលផ្ដុំមតិយោបល់របស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកក្នុងកម្រងសំណួរបង្ហាញថា ក្នុងចំណោមវិធានការដែលថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកបានលើកឡើងខាងលើ វិធានការដែលគួរឱ្យចាប់អារម្មណ៍ជាងគេគឺ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកបានឯកភាពឱ្យវិទ្យាល័យដែលខ្វះគ្រូឧត្ដម យកគ្រូកម្រិតមូលដ្ឋានដែលមានសមត្ថភាពខ្ពស់ទៅជួយបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ពីព្រោះដំណោះស្រាយនេះមានថ្នាក់

ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដល់ទៅ៩រូប ក្នុងចំណោម១១រូប ដែលបានផ្ដល់បទសម្ភាសន៍ សុទ្ធតែបានលើកឡើងពីដំណោះស្រាយនេះ។ វិធានការនេះជាទិន្នន័យមួយដ៏សំខាន់សម្រាប់ក្រសួងអប់រំ យុវជន និងកីឡាយកទៅផ្សព្វផ្សាយដល់ខេត្តផ្សេងៗទៀត។

### ៤.៣.៦.វិធានការដោះស្រាយបញ្ហាបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម

ស្រុកដែលមានវិទ្យាល័យលើសគ្រូបង្រៀនកម្រិតឧត្តមគឺស្រុកកណ្ដាលស្ទឹង ដែលលើសដល់ទៅ៩នាក់នៅក្នុងវិទ្យាល័យ ហស កំពង់កន្ទួត។ ហើយវិធានការដោះស្រាយបញ្ហាប្រឈមដោយសារលើសគ្រូដែលការិយាល័យអប់រំ យុវជន និងកីឡាស្រុកកណ្ដាលស្ទឹងបានអនុវត្តនោះគឺស្នើសុំគោលការណ៍ពីមន្ទីរដើម្បីពង្រាយគ្រូទៅសាលារៀនដែលខ្វះ។ នេះបើតាមការផ្ដល់ចម្លើយរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាស្រុកកណ្ដាលស្ទឹង។

## ៤.៤.របកគំហើញពីកម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងវិទ្យាល័យ

**ក្រាប៦ ភេទរបស់គណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្ដល់បទសម្ភាសន៍**




តាមក្រាប៦ គណៈគ្រប់គ្រងវិទ្យាល័យដែលបានបានចូលរួមផ្ដល់បទសម្ភាសន៍មានចំនួន១១នាក់ ដែលក្នុងនោះមានភេទប្រុសទាំង១១រូប ស្មើនឹង១០០%។ ទិន្នន័យនេះបង្ហាញថា អ្នកចូលរួមផ្ដល់បទសម្ភាសគឺ ភេទប្រុសទាំងអស់។

**ក្រាប៧ តួនាទីរបស់គណៈគ្រប់គ្រងសាលាដែលបានចូលរួមផ្តល់បទសម្ភាសន៍**




តាមក្រាប៧ បង្ហាញថាគណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្តល់បទសម្ភាសន៍មានចំនួន ១១នាក់ ក្នុងនោះ៦នាក់ជានាយកសាលា ស្មើនឹង៥៤.៥% និង៥នាក់ជានាយករង ស្មើនឹង៤៥.៥%។ ទិន្នន័យនេះបង្ហាញថា គណៈគ្រប់គ្រងវិទ្យាល័យដែលចូលរួមផ្តល់បទសម្ភាសន៍ភាគច្រើនជានាយកសាលា។

**ក្រាប៨ អាយុរបស់គណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្តល់បទសម្ភាសន៍**




តាមក្រាប៨ បង្ហាញថាគណៈគ្រប់គ្រងវិទ្យាល័យដែលបានចូលរួមផ្តល់បទសម្ភាសន៍មានចំនួន ១១នាក់ ក្នុងនោះអាយុចន្លោះពី៣០ ដល់៤០ឆ្នាំគ្មាន អាយុចន្លោះពី៤០ ដល់ ៥០ឆ្នាំមានចំនួន៨នាក់

ស្មើនឹង ៧២.៧៣% និងចន្លោះអាយុពី៥០ ដល់ ៦០ឆ្នាំមាន៣នាក់ ស្មើនឹង២៧.២៧%។ ទិន្នន័យនេះបង្ហាញថា គណៈគ្រប់គ្រងសាលាដែលចូលរួមផ្តល់បទសម្ភាសន៍ភាគច្រើនមានអាយុចន្លោះពី៥០ ដល់ ៦០ឆ្នាំ។

**ក្រាប៩ តម្រូវការ(ខ្វះ) គ្រូបង្រៀនកម្រិតឧត្តមតាមវិទ្យាល័យ**




តាមក្រាប៩ បង្ហាញថា មានវិទ្យាល័យចំនួន១០ មានតម្រូវការ(ខ្វះ) គ្រូបង្រៀនកម្រិតឧត្តមក្នុងចំណោមវិទ្យាល័យទាំង១១ ដែលបានជ្រើសរើស ។ តម្រូវការសរុបក្នុងវិទ្យាល័យទាំង១០ គឺមានចំនួន ៦០នាក់ ក្នុងនោះវិទ្យាល័យជ័យវរ្ម័នទី៧ ស្ថិតនៅក្នុងស្រុកកៀនស្វាយខ្វះច្រើនជាងគេដល់ទៅ១២នាក់ ហើយវិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមច្រើនបន្ទាប់មានវិទ្យាល័យពីរគឺវិទ្យាល័យហ៊ុន សែន ស្អាង ស្ថិតនៅក្នុងស្រុកស្អាង និងវិទ្យាល័យសិត្បូស្ថិតនៅក្រុងតាខ្មៅ ដែលខ្វះដល់ទៅ១១នាក់។ ដោយឡែកវិទ្យាល័យដែលខ្វះគ្រូកម្រិតឧត្តមតិចជាងគេគឺវិទ្យាល័យហ៊ុនសែនកោះចិនដែលខ្វះតែ១នាក់ប៉ុណ្ណោះ។

## ក្រាប១០ តម្រូវការគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យតាមមុខវិជ្ជា




☞សម្គាល់៖ K=ភាសាខ្មែរ, I=សីលធម៌ពលរដ្ឋវិជ្ជា, H=ប្រវត្តិវិទ្យា, G=ភូមិវិទ្យា, M=គណិតវិទ្យា, P=រូបវិទ្យា, C=គីមីវិទ្យា, B=ជីវវិទ្យា, Es=ផែនដីវិទ្យា, Ec=សេដ្ឋកិច្ចវិទ្យា, E=ភាសាអង់គ្លេស, IT=ព័ត៌មានវិទ្យា

តាមក្រាប១០ បង្ហាញថា មុខវិជ្ជាដែលខ្វះច្រើនជាងគេ គឺមុខវិជ្ជាព័ត៌មានវិទ្យា។ ក្នុងចំណោមវិទ្យាល័យជ្រើសរើសទាំង១០ មានវិទ្យាល័យចំនួន៦ខ្វះគ្រូបង្រៀនកម្រិតឧត្តមមុខវិជ្ជាព័ត៌មានវិទ្យានេះ ដែលខ្វះរហូតដល់ទៅ៩នាក់ ហើយក្នុងនោះវិទ្យាល័យដែលខ្វះមុខវិជ្ជានេះច្រើនជាងគេគឺវិទ្យាល័យហស.ស្អាង ដែលខ្វះដល់ទៅ៣នាក់។ រីឯវិទ្យាល័យដែលខ្វះមុខវិជ្ជានេះច្រើនបន្ទាប់គឺវិទ្យាល័យជ័យវរ្ម័នទី៧ ដែលខ្វះចំនួន២នាក់។ ក្រៅពីនេះវិទ្យាល័យ៤ផ្សេងទៀត ខ្វះគ្រូកម្រិតឧត្តមមុខវិជ្ជានេះ១នាក់ដូចៗគ្នា។ សម្រាប់មុខវិជ្ជាដែលខ្វះច្រើនបន្ទាប់គឺមុខវិជ្ជាភាសាអង់គ្លេស មានវិទ្យាល័យចំនួន៥ខ្វះមុខវិជ្ជានេះ ដែលខ្វះចំនួន៨នាក់ ហើយក្នុងនោះ វិទ្យាល័យដែលខ្វះមុខវិជ្ជានេះច្រើនជាងគេ គឺវិទ្យាល័យជ័យវរ្ម័នទី៧ ហើយវិទ្យាល័យស្អាង និងវិទ្យាល័យសិត្បូខ្វះចំនួន២នាក់ដូចៗគ្នា រីឯវិទ្យាល័យ២ទៀតខ្វះមុខវិជ្ជានេះ១នាក់ដូចៗគ្នាផងដែរ។ ចំណែកមុខវិជ្ជាដែលខ្វះច្រើនបន្ទាប់មកទៀតនោះគឺមុខវិជ្ជាភូមិវិទ្យា។ មានវិទ្យាល័យចំនួន៦ខ្វះមុខវិជ្ជាភូមិវិទ្យា ដែលខ្វះដល់ទៅ៧នាក់ក្នុងចំណោមវិទ្យាល័យទាំង១០។ មុខវិជ្ជានេះខ្វះច្រើន

ជាងគេនៅវិទ្យាល័យជ័យវរ្ម័នទី៧ ដែលខ្វះចំនួន២នាក់ ហើយវិទ្យាល័យ៥ទៀតខ្វះមុខវិជ្ជានេះ១នាក់ៗដូចគ្នា។ ក្រៅពីមុខវិជ្ជាទាំងបីខាងលើនៅមានមុខវិជ្ជាផ្សេងៗទៀតដែលខ្វះផងដែរ ដូចជាមុខវិជ្ជាសីលធម៌-ពលរដ្ឋ និងមុខវិជ្ជាផែនដីវិទ្យាខ្វះ៦នាក់ដូចគ្នា មុខវិជ្ជាជីវវិជ្ជា និងសេដ្ឋកិច្ចខ្វះ៥នាក់ មុខវិជ្ជាប្រវត្តិវិទ្យា និងគណិតវិទ្យាខ្វះ៤នាក់ មុខវិជ្ជាភាសាខ្មែរខ្វះ៣នាក់ និងមុខវិជ្ជារូបវិទ្យា និងគីមីវិទ្យាខ្វះ១នាក់ៗ ដែលតិចជាងគេ។

## ក្រាប១១ គ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការ និងលើសតាមមុខវិជ្ជា




តាមក្រាប១១ បង្ហាញថា ក្នុងចំណោមវិទ្យាល័យទាំង១១ ដែលបានជ្រើសរើស មានវិទ្យាល័យ១ ដែលមានគ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការ និងមានវិទ្យាល័យចំនួន២ លើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជា។ តាមក្រាបនេះបង្ហាញថាគ្រូបង្រៀនកម្រិតឧត្តមដែលលើសតម្រូវ នៅវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាលជាស៊ីម ព្រែកអញ្ចាញមានចំនួន២៤នាក់ ក្នុងនោះមុខវិជ្ជាគណិតវិទ្យាលើសច្រើនជាងគេដល់ទៅ៦នាក់។ មុខវិជ្ជាបន្ទាប់គឺសីលធម៌-ពលរដ្ឋវិជ្ជាលើស៤នាក់ ភាសាខ្មែរលើស៣នាក់ គីមីវិទ្យា និងព័ត៌មានវិទ្យាលើស២នាក់ដូចគ្នា និងមុខវិជ្ជាផ្សេងៗទៀតសុទ្ធតែលើស១នាក់ៗដូចៗគ្នា រួមមានប្រវត្តិវិទ្យា ភូមិវិទ្យា រូបវិទ្យា ជីវវិទ្យា ផែនដីវិទ្យា សេដ្ឋកិច្ចវិទ្យា និងភាសាអង់គ្លេស។ ចំណែកឯបញ្ហា

លើសតាមមុខវិជ្ជាខ្លះកើតមាននៅវិទ្យាល័យព្រែកស្លែង និងវិទ្យាល័យហ៊ុន សែនកំពង់ត្នំ ដែលលើសសរុប ចំនួន៧នាក់ គឺមុខវិជ្ជាភាសាខ្មែរ២នាក់ គណិតវិទ្យា២នាក់ រូបវិទ្យា១នាក់ និងមុខវិជ្ជាគីមីវិទ្យា២នាក់។

**ក្រាប១២ ទីតាំងវិទ្យាល័យទាំងដែលបានជ្រើសរើសទាំង១១**




តាមក្រាប១២ បង្ហាញថាមានវិទ្យាល័យមាន៣ស្ថិតនៅតំបន់ទីប្រជុំជន ស្មើនឹង២៧.២៧% និងមានវិទ្យាល័យចំនួន៨ស្ថិតនៅតំបន់ជនបទ ដែលស្មើនឹង៧២.៧៣%។ ទិន្នន័យនេះបង្ហាញថា វិទ្យាល័យភាគច្រើនស្ថិតនៅតំបន់ជនបទ។

ក្រាប១៣ ការសាកសួរព័ត៌មានតម្រូវការគ្រូបង្រៀនកម្រិតឧត្តមតាមវិទ្យាល័យរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មុននឹងបញ្ជូនគ្រូថ្មីចូល




តាមក្រាប១៣ បង្ហាញថាមានវិទ្យាល័យចំនួន១១ដែលត្រូវបានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសាកសួរជាមុន មុននឹងបញ្ជូនគ្រូចេញថ្មីចូល ដែលស្មើនឹង១០០%។ ទិន្នន័យនេះបង្ហាញថាមន្ទីរអប់រំ យុវជន និងកីឡាខេត្តសុទ្ធតែបានសាកសួរជាមុនអំពីតម្រូវការគ្រូបង្រៀនកម្រិតមុននឹងបញ្ជូនគ្រូចេញថ្មីចូលវិទ្យាល័យណាមួយ។

### ៥.៥.១.មូលហេតុខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ

ក្នុងចំណោមវិទ្យាល័យដែលបានជ្រើសរើសទាំង១១ មានវិទ្យាល័យចំនួន១០ ដែលមានបញ្ហាខ្វះគ្រូបង្រៀនកម្រិតឧត្តម។ មូលហេតុដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតនៅវិទ្យាល័យដែលគណៈគ្រប់គ្រងវិទ្យាល័យទាំង១០បានលើកឡើងមានដូចជា ការជ្រើសរើសគ្រូកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡាមានចំនួនតិចពេកក្នុងមួយឆ្នាំៗ មន្ទីរអប់រំ យុវជន និងកីឡាបញ្ជូនគ្រូមកច្រើនខុសឯកទេស មន្ទីរអប់រំ យុវជន និងកីឡាបញ្ជូនគ្រូចេញថ្មីទៅសាលាដែលខ្វះខាតច្រើនជាងគេ កំណើនសិស្សមធ្យមសិក្សាទុតិយភូមិដោយសារការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិជាប់ច្រើន ការផ្លាស់(ផ្ទេរ)ចេញ

មានគ្រូមូលដ្ឋានច្រើននៅក្នុងវិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម ទីតាំងអនុវិទ្យាល័យត្រូវពង្រីកជាវិទ្យាល័យព្រមៗគ្នាក្នុងខេត្ត វិទ្យាល័យដែលខ្វះគ្រូមានទីតាំងនៅតំបន់ជនបទ និងសាលាទើបតែបង្កើតថ្មី(អនុវិទ្យាល័យ ទៅជាវិទ្យាល័យ)ជាដើម។

យើងសង្កេតឃើញថា មានមូលហេតុជាច្រើនដែលនាំឱ្យមានកង្វះខាតគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ហើយមូលហេតុទាំងអស់ខាងលើភាគច្រើនមានការលើកឡើងមូលហេតុផ្សេងៗគ្នា។ ដោយឡែកគណៈគ្រប់គ្រងខ្លះបានលើកឡើងមូលហេតុដូចគ្នាដូចជា ការជ្រើសរើសគ្រូកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡាមានចំនួនតិចពេកក្នុងមួយឆ្នាំៗ ដែលមានគណៈគ្រប់គ្រងវិទ្យាល័យ៣រូបបានលើកឡើងពីមូលហេតុនេះ។ ក្រៅពីនេះ មានមូលហេតុមួយចំនួនទៀតមានគណៈគ្រប់គ្រង២រូបបានលើកឡើងមូលហេតុដូចគ្នាគឺ មន្ទីរអប់រំ យុវជន និងកីឡាបញ្ជូនគ្រូចេញថ្មីទៅសាលាដែលខ្វះខាតច្រើនជាងគេ និងកំណើនសិស្សមធ្យមសិក្សាទុតិយភូមិដោយសារការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិជាប់ច្រើន។ នេះបើតាមទិន្នន័យដែលទទួលបានពីការសម្ភាសគណៈគ្រងគ្រងវិទ្យាល័យទាំង១១រូប។

### ៤.៤.២.មូលហេតុលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជាខ្លះ

ក្នុងចំណោមវិទ្យាល័យទាំង១១ ដែលបានជ្រើសរើស មានតែវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាលជាស៊ីមព្រែកអញ្ចាញដែលស្ថិតនៅក្នុងស្រុកមុខកំពូលប៉ុណ្ណោះ ដែលលើសគ្រូបង្រៀនកម្រិតឧត្តម ហើយមានវិទ្យាល័យ២ ដែលលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាខ្លះ គឺវិទ្យាល័យព្រែកស្លែងក្នុងស្រុកកណ្តាលស្ទឹង និងវិទ្យាល័យហ៊ុន សែន កំពង់ភ្នំក្នុងស្រុកលើកដែក។

ចំពោះមូលហេតុ ដែលលើសគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាលជាស៊ីមព្រែកអញ្ចាញគឺដោយសារវិទ្យាល័យនេះជាសាលារៀនជំនាន់ថ្មី។

ចំណែកឯមូលហេតុដែលនាំឱ្យលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាខ្លះ គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង២ខាងបានលើកឡើងផ្សេងៗគ្នា។ គណៈគ្រងវិទ្យាល័យព្រែកស្លែងបានលើកឡើងថា មូលហេតុដែលលើសតាមមុខវិជ្ជា គឺដោយសារកម្មវិធីពន្លឿនពីគ្រូកម្រិតមូលដ្ឋានទៅជាគ្រូកម្រិតឧត្តមរបស់

ក្រសួងអប់រំ យុវជន និងកីឡា។ រីឯគណៈគ្រប់គ្រងវិទ្យាល័យហ៊ុន សែនកំពង់ភ្នំវិញបានលើកឡើងថា មូលហេតុដែលលើសគឺបណ្ដាលមកពីគ្រូប្ដូរចូលដើម្បីបានមកនៅស្រុកកំណើត ឬដើម្បីបានមកបម្រើការនៅជិតផ្ទះ។

### ៤.៤.៣.បញ្ហាប្រឈម និងផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តម

**បញ្ហាប្រឈម**

តាមលទ្ធផលដែលទទួលបានពីការសម្ភាសគណៈគ្រប់គ្រងវិទ្យាល័យទាំង១០ ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម បញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តមដែលគណៈគ្រប់គ្រងទាំងនោះបានលើកឡើងមានរួមមាន គ្រូបង្រៀនខុសក្របខ័ណ្ឌ(គ្រូកម្រិតមូលដ្ឋានបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ) គ្រូបង្រៀនខុសឯកទេស គ្រូបង្រៀនមិនបានស៊ីជម្រៅ និងមិនចំគោលបំណងនាំឱ្យការសិក្សារបស់សិស្សមានលទ្ធផលមិនសូវល្អ ពិបាករៀបចំសេវាបង្រៀន រៀបសិស្សខុសនិយាមសិស្សថ្នាក់(អាចមានលើសពី៥០នាក់ ក្នុង១បន្ទប់) គ្រូបង្រៀនខ្លះមានម៉ោងបង្រៀនច្រើន នាយក នាយករង បុគ្គលិកទីចាត់ការចេញទៅជួយបង្រៀននាំឱ្យប៉ះពាល់ការងារគ្រប់គ្រងសាលារៀនជាដើម។ ក្នុងចំណោមបញ្ហាប្រឈមទាំងអស់ខាងលើបញ្ហាប្រឈមដែលគួរយកចិត្តទុកដាក់ជាងគេគឺ គ្រូបង្រៀនខុសក្របខ័ណ្ឌ(គ្រូកម្រិតមូលដ្ឋានបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ) ពីព្រោះបញ្ហាប្រឈមនេះនាំទៅរកបញ្ហាប្រឈមផ្សេងទៀត និងត្រូវបានលើកឡើងដូចៗគ្នាពីគណៈគ្រប់គ្រងវិទ្យាល័យដល់ទៅ៧រូប ក្នុងចំណោមគណៈគ្រប់គ្រងទាំង១០រូបខាងលើ។ នេះបើតាមការសង្កេតរបស់អ្នកសិក្សាស្រាវជ្រាវទៅលើទិន្នន័យដែលទទួលបានពីកម្រងសំណួរ។

## ផលប៉ពាល់

ក្រាប១៤ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្ដាលឆ្នាំសិក្សា២០១៧-២០១៨ និង២០១៨-២០១៩




តាមក្រាប១៤ បង្ហាញថា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ គិតត្រឹមរយៈពេលពីរឆ្នាំចុងក្រោយនេះ ក្នុងខេត្តកណ្ដាលទទួលលទ្ធផលមិនសូវល្អនោះទេ ដោយឆ្នាំសិក្សា២០១៧-២០១៨ ទទួលបានលទ្ធផលសរុប ៧៣.៥៩% និងឆ្នាំសិក្សា ២០១៩-២០១៩ ទទួលបាន ៧៣.៨០%ប៉ុណ្ណោះ។ កង្វះគ្រូបង្រៀនកម្រិតឧត្តមគឺជាមូលហេតុដ៏សំខាន់មួយដែលធ្វើឱ្យខេត្តកណ្ដាល ទទួលបានលទ្ធផលប្រឡងមិនសូវល្អ ដូចទៅនឹងការលើកឡើងរបស់គណៈគ្រប់គ្រងវិទ្យាល័យភាគច្រើនដែលបានលើកឡើងថា កង្វះគ្រូបង្រៀនកម្រិតឧត្តមធ្វើឱ្យសិស្សនៅកម្រិតមធ្យមសិក្សាទទួលបានលទ្ធផលសិក្សាមិនសូវល្អ។

ក្រាប១៥ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៧-២០១៨ នៅវិទ្យាល័យគោលដៅ ដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម




តាមក្រាប១៥ បង្ហាញថា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុង ឆ្នាំសិក្សា២០១៧-២០១៨ វិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមគឺសិស្សទទួលបានលទ្ធផលមិនសូវល្អជាពិសេសថ្នាក់វិទ្យាសាស្ត្រ។ ជាក់ស្តែង វិទ្យាល័យ ហ៊ុនសែនស្អាង ទទួលបានលទ្ធផលសិស្សប្រឡងជាប់ទាបជាងគេគឺបានត្រឹម៣៥.៥៩% ប៉ុណ្ណោះ ហើយខ្ពស់ជាងគេគឺវិទ្យាល័យហ៊ុនសែនថ្នល់ទទឹងបានត្រឹមតែ៧៥.៩៧% ប៉ុណ្ណោះសម្រាប់ថ្នាក់វិទ្យាសាស្ត្រ។

**ក្រាប១៦ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាល័យគោលដៅដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម**




តាមក្រាប១៦ បង្ហាញថា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុង ឆ្នាំសិក្សា២០១៨-២០១៩ លទ្ធផលនៅវិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមមានការប្រែប្រួលខ្លះៗដោយមានការកើនឡើងជាងឆ្នាំសិក្សា ២០១៧-២០១៨ ប៉ុន្តែលទ្ធផលនេះមិនទាន់ល្អប្រសើរនៅឡើយទេពិសេសសម្រាប់ថ្នាក់វិទ្យាសាស្ត្រ។ ជាក់ស្តែង វិទ្យាល័យព្រែកលួងលទ្ធផលសិស្សប្រឡងជាប់មានត្រឹមតែ៥៩.៣៨% ប៉ុណ្ណោះសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និង៦៩% សម្រាប់លទ្ធផលសរុបរួម។

សរុបមក តាមក្រាប១៤ ក្រាប១៥ និងក្រាប១៦ យើងអាចសន្និដ្ឋានបានថាកង្វះគ្រូបង្រៀនកម្រិតឧត្តម គឺពិតជាបានធ្វើឱ្យមានផលប៉ះពាល់ដល់គុណភាពអប់រំនៅកម្រិតមធ្យមសិក្សាទុយភូមិគួរឱ្យព្រួយបារម្ភណ៍ដែលត្រូវតែយកចិត្តទុកដាក់។

### ៤.៤.៤.បញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជា

បញ្ហាប្រឈមដែលបណ្តាលមកពីការលើសគ្រូបង្រៀនកម្រិតឧត្តម កើតមានតែនៅក្នុងវិទ្យាល័យមួយប៉ុណ្ណោះក្នុងចំណោមវិទ្យាល័យដែលបានជ្រើសរើសទាំង១១ គឺវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាលជាស៊ីមព្រៃកអញ្ចាញ។ ហើយបញ្ហាប្រឈមនោះគឺពិបាកក្នុងការបែងចែកភារកិច្ចឱ្យគ្រូបង្រៀនព្រោះអត់ថ្នាក់ឱ្យគ្រូបង្រៀន។ ចំណែកឯបញ្ហាប្រឈមដែលបណ្តាលមកពីការលើសគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាខ្លះ កើតមាននៅវិទ្យាល័យ២ គឺវិទ្យាល័យព្រែកស្លែង និងវិទ្យាល័យហ៊ុន សែនកំពង់ភ្នំដែលជួបបញ្ហាប្រឈមតែមួយដូចគ្នាគឺគ្រូបង្រៀនកម្រិតឧត្តមមុខវិជ្ជាដែលលើសនោះបង្រៀនមិនគ្រប់តាមនិយាមម៉ោងកំណត់។

### ៤.៤.៥.ដំណោះស្រាយបញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ

តាមការផ្តល់ទិន្នន័យរបស់គណៈគ្រប់គ្រងវិទ្យាល័យទាំង១០ ដែលវិទ្យាល័យមានបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្តម គណៈគ្រប់គ្រងទាំងនោះបានលើកឡើងនូវដំណោះស្រាយមួយចំនួនដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើរួមមាន ដាក់សំណើរទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តជារៀងរាល់ឆ្នាំទាក់ទងទៅវិទ្យាល័យដែលនៅជិត ដើម្បីសុំគ្រូបង្រៀនកម្រិតឧត្តមមកជួយបង្រៀនដោយគិតប្រាក់ម៉ោងបន្ថែម (ខ្ចីគ្រូពីសាលាផ្សេង) មិនចុះហត្ថលេខា លើឯកសារផ្លាស់ប្តូរទីកន្លែងធ្វើការ(ផ្ទេរ) របស់បុគ្គលិកបង្រៀន ដែលបំពេញភារកិច្ចមិនល្អ និងមិនគ្រប់ឆ្នាំ ទន់ភ្លន់ ម៉ឺងម៉ាត់ តម្លាភាពក្នុងការរៀបចំសេវាបង្រៀនជូនបុគ្គលិក អនុគ្រោះដល់បុគ្គលិកមានទីលំនៅឆ្ងាយ ហើយលើកទឹកចិត្តដល់អ្នកមានទីលំនៅជិត(កោតសរសើរជាពាក្យសំដី ប័ណ្ណសរសើរ) លើកទឹកចិត្តគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យបន្តការសិក្សាថ្នាក់

បរិញ្ញាបត្រដើម្បីបង្កើនចំណេះដឹង ជំរុញគ្រូបង្រៀនកម្រិតមូលដ្ឋាន ឱ្យស្រាវជ្រាវ ប្រជុំពិភាក្សាជាមួយគ្រូបង្រៀនកម្រិតឧត្តមតាមមុខវិជ្ជាដែលគាត់បង្រៀន។

យោងតាមទិន្នន័យខាងលើ យើងឃើញថា មានដំណោះស្រាយជាច្រើនដែលគណៈគ្រប់គ្រងវិទ្យាល័យទាំង១០បានលើកឡើង ក្នុងការដោះស្រាយបញ្ហាប្រឈមដោយសារកង្វះគ្រូបង្រៀនកម្រិតឧត្តម។ ប៉ុន្តែតាមការសង្កេតទិន្នន័យក្នុងកម្រងសំណួរសម្ភាសន៍ អ្នកសិក្សាស្រាវជ្រាវរកឃើញថា ការដាក់សំណើទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជារៀងរាល់ឆ្នាំ ជាដំណោះស្រាយដែលពេញនិយមជាងគេ ពីព្រោះមានគណៈគ្រប់គ្រងវិទ្យាល័យដល់ទៅ៧បានលើកឡើងពីដំណោះស្រាយនេះ បើទោះបីជាវាមានរយៈពេលវែងក៏ដោយ។

## ៤.៤.៦.ដំណោះស្រាយបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម និងលើសតាមមុខវិជ្ជា

បញ្ហាលើសគ្រូបង្រៀនកម្រិត កើតមានតែនៅក្នុងវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាលជាស៊ីម ព្រែកអញ្ចាញមួយប៉ុណ្ណោះក្នុងចំណោមវិទ្យាល័យទាំង១១ ដែលបានជ្រើសរើស។ ហើយវិធានការដោះស្រាយបញ្ហាខាងលើ ដែលវិទ្យាល័យនេះបានប្រើមានដូចជា៖

- ធ្វើរបាយការណ៍ជូនការិយាល័យអប់រំស្រុក/មន្ទីរ
- បែងចែកភារកិច្ចឱ្យគ្រូមកប្រចាំការតាមរបបម៉ោងកំណត់
- ឱ្យគ្រូជួយធ្វើកិច្ចការសាលាផ្សេងៗតាមតម្រូវការជាក់ស្តែង តាមថ្ងៃដែលគាត់មកប្រចាំការ

ដោយឡែក ដំណោះស្រាយបញ្ហាលើសគ្រូកម្រិតឧត្តមតាមមុខវិជ្ជាដែលវិទ្យាល័យព្រែកស្លែង បានអនុវត្តន៍គឺចែកម៉ោងគ្នាបង្រៀន ចំណែកវិទ្យាល័យហ៊ុន សែនកំពង់ភ្នំវិញ គឺរាយការណ៍ទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តឱ្យបានដឹង។

តាមទិន្នន័យដែលបានពីការសម្ភាសថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យយើងអាចសន្និដ្ឋាន

បានថា ការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅក្នុងខេត្តកណ្តាលគឺនៅមិនទាន់មានភាពឆ្លើយតបទៅនឹងតម្រូវការនៅឡើយទេ ដោយវិទ្យាល័យ១០ក្នុងចំណោមវិទ្យាល័យ២៩ដែលខ្វះគ្រូបង្រៀនកម្រិតមានតម្រូវការ(ខ្វះ) រហូតដល់៦០នាក់ ហើយក្នុងចំណោមនោះមុខវិជ្ជាដែលខ្វះមានដូចជា ព័ត៌មានវិទ្យា ភាសាអង់គ្លេស គណិតវិទ្យា ជីវវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងប្រវត្តិវិទ្យាជាដើម។ ជាមួយគ្នានេះដែរក៏មានវិទ្យាល័យខ្លះមានគ្រូបង្រៀនកម្រិតឧត្តមលើសតម្រូវការ និងវិទ្យាល័យខ្លះលើសតាមមុខវិជ្ជាផងដែរ។ ជាក់ស្តែងក្នុងចំណោមវិទ្យាល័យដែលបានជ្រើសរើសរើសទាំង១១មានវិទ្យាល័យ១ លើសតម្រូវការគ្រូបង្រៀនកម្រិតឧត្តម ដែលលើសគ្រូចំនួន២៤នាក់ប៉ុន្តែដោយសារវិទ្យាល័យនោះជាសាលារៀនជំនាន់ថ្មី។

មួយវិញទៀត តាមទិន្នន័យខាងលើឃើញថាកង្វះ គ្រូបង្រៀនកម្រិតឧត្តមគឺបាននាំមកនូវបញ្ហាប្រឈមជាច្រើនដល់វិទ្យាល័យ ហើយបញ្ហាប្រឈមដែលត្រូវយកចិត្តទុកដាក់ខ្លាំងជាងគេគឺ គ្រូបង្រៀនខុសក្របខ័ណ្ឌ(គ្រូកម្រិតមូលដ្ឋានបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ) បង្រៀនខុសឯកទេស ការបង្រៀនមិនបានស៊ីជម្រៅ និងមិនចំគោលបំណង ដែលនាំឱ្យមានផលប៉ះពាល់ដល់គុណភាពអប់រំ ដោយសិស្សទទួលបានលទ្ធផលមិនសូវល្អឡើយក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យបានសហការគ្នាចាត់វិធានការមួយចំនួនដើម្បីដោះស្រាយបញ្ហាខាងលើជាបណ្តោះអាសន្ន ប៉ុន្តែមិនសូវទទួលបានល្អឡើយ។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរតែយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា ចំពោះបញ្ហាប្រឈមដែលនាំឱ្យមានផលប៉ះពាល់ដូចដែលបានលើកឡើងខាងលើ។

# ជំពូកទី៥៖

# សន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះបានផ្តល់ជារបកគំហើញថ្មីមួយ ស្តីពី តម្រូវការ និងការផ្គត់គ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តកណ្តាល និងសិក្សាអំពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមដែលបាននឹងកំពុងអនុវត្តបច្ចុប្បន្ន ព្រមទាំងសិក្សាពីផលប៉ះពាល់នៃកង្វះគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តកណ្តាលដោយផ្អែកលើលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីជាជំនួយស្មារតីដល់ក្រសួងអប់រំ យុវជន និងកីឡា។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវអាចសនិដ្ឋានបានថា ការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅក្នុងខេត្តកណ្តាល គឺមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា(វិទ្យាល័យ)នៅឡើយទេ។ ហើយកង្វះគ្រូបង្រៀនកម្រិតឧត្តមបានធ្វើឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា គ្រូបង្រៀនខុសក្របខ័ណ្ឌ ខុសឯកទេសដែលធ្វើឱ្យមានផលប៉ះពាល់ដល់គុណភាពអប់រំនៅកម្រិតវិទ្យាល័យគឺក្នុងវិទ្យាល័យនានាដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមទទួលបានលទ្ធផលមិនសូវល្អក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

## ៥.២.សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយផ្ទាល់ នៅតាមវិទ្យាល័យចំនួន១១ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល និងការស្រាវជ្រាវទិន្នន័យដែលមានស្រាប់នៅគ្រប់វិទ្យាល័យបានបង្ហាញឱ្យឃើញថា ការផ្គត់ផ្គង់គ្រូបង្រៀនឱ្យបានត្រឹមត្រូវតាមមុខវិជ្ជាឯកទេសតម្រូវការ មិនទាន់បានឆ្លើយតបនៅឡើយ។ កត្តានេះមិនអាចអូសបន្លាយក្នុងស្ថានភាពដដែលនេះតទៅទៀតបានទេ បើមិនបានដោះស្រាយទាន់ពេលវេលា នោះនឹងធ្វើឱ្យគុណភាពអប់រំ នៅកម្រិតវិទ្យាល័យនានាក្នុងខេត្តកណ្តាលមិនឆ្លើយតបទៅ

នឹងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ។ ក្នុងន័យនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តួចផ្តើមលើកឡើងនូវសំណូមពរ ដល់ក្រសួង មន្ទីរ និងអ្នកពាក់ព័ន្ធដូចខាងក្រោម៖

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - គួរតែបន្តអនុវត្តន៍គោលការណ៍ក្នុងការជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមដោយតម្រូវឱ្យបេក្ខជនជ្រើសរើសវិទ្យាល័យមុននឹងមកចុះឈ្មោះប្រឡង
  - គួរបន្ថែមចំនួនជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមប្រចាំឆ្នាំ
  - ក្នុងការជ្រើសរើសគ្រូបង្រៀន គួរផ្តល់ឱកាសឱ្យច្រើនដល់អ្នកមូលដ្ឋានដើម្បីកុំឱ្យមានការផ្លាស់ប្តូរទីកន្លែងបម្រើការងារ
  - ផ្លាស់ប្តូរ(ចល័ត)គ្រូបង្រៀនកម្រិតឧត្តម និងនាយកវិទ្យាល័យនៅក្នុងខេត្ត៥ឆ្នាំម្តង ដើម្បីអាចពង្រាយគ្រូចេញពីទីប្រជុំជនទៅជនបទបាន
- **ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យ៖**
  - បន្តការសហការគ្នាឱ្យកាន់តែល្អប្រសើរថែមទៀតក្នុងការចាត់ចែង ឬប្រើប្រាស់គ្រូបង្រៀនកម្រិតឧត្តម ដើម្បីជួយដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្ត
  - រៀបចំបញ្ជីតម្រូវការគ្រូបង្រៀនកម្រិតឧត្តមប្រចំឆ្នាំឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ក្រែងមានភាពខ្វះចន្លោះ ដែលអាចឱ្យក្រសួងធ្វើការប្រឡងជ្រើសរើសគ្រូបង្រៀនថ្មីមិនចំឯកទេសដែលត្រូវការ ឬមិនត្រូវទីតាំងវិទ្យាល័យដែលខ្វះពិតប្រាកដ។
- **អ្នកស្រាវជ្រាវបន្ត៖**

ការសិក្សាស្រាវជ្រាវទៅលើតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម គឺធ្វើឡើងតែក្នុងខេត្តកណ្តាល និងជ្រើសវិទ្យាល័យក្នុងខេត្តតែ១១ប៉ុណ្ណោះ ដែលជាកត្តាមួយអាចធ្វើឱ្យមានភាពខ្វះចន្លោះ និងមិនទាន់គ្រប់ជ្រុងជ្រោយ។ ដូចនេះអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់សិក្សាស្វែងយល់អំពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម សូមពង្រីកវិសាលភាពទៅខេត្តដទៃទៀត ឬវិទ្យាល័យ

ផ្សេងៗទៀតក្នុងខេត្តកណ្តាលឱ្យកាន់តែទូលាយ  ដើម្បីដឹងឱ្យកាន់តែច្បាស់អំពីស្ថានភាពនៃការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# ឯកសារយោង


កើត គីមហេង (២០១៨) ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមវិទ្យាល័យនានានៅកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) គោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) គោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) តារាងបែងចែកក្របខណ្ឌប្រឡងជ្រើសរើសគរុនិសិត្សកម្រិតឧត្តម(បរិញ្ញា+១) ជំណាន់ទី២៥។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៩-២០២៣។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សេចក្ដីជូនដំណឹងលេខ ៣១៣០ អយក.បល។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សេចក្ដីណែនាំស្ដីពីការគ្រប់គ្រងគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សេចក្ដីណែនាំស្ដីពីការប្រឡងជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) គោលនយោបាយស្តីពីគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា (២០១២) គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ។

ឆាន សាំងលីន និងសុខ សោភា (២០១៨) របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ការគ្រប់គ្រងធនធានមនុស្ស។

ជួន ណាត (១៩៦៧) វចនានុក្រមខ្មែរ ភ្នំពេញ។

នាយកដ្ឋានបុគលិក (២០២០) របាយការណ៍ស្តីពីស្ថានភាពអប់រំ ឆ្នាំសិក្សា ២០១៨-២០១៩។

ព្រះរាជក្រឹត្យស្តីពីលក្ខខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម(២០០១)។

ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ (១៩៩៧)។

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ២០១៩-២០២៣។

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤។

រាជរដ្ឋាភិបាលកម្ពុជា (២០១៦) អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។

រាជរដ្ឋាភិបាលកម្ពុជា (២០០៨) អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

អ៊ុំ សាខន (២០១៧) មគ្គុទេសក៍សម្រាប់គ្រូបង្រៀនថ្មី។

A.Omebe, D. (2014). HUMAN RESOURCE MANAGEMENT IN EDUCATION: ISSUES AND CHALLENGES.

*Inc.* (2020). Retrieved from INC. EDITORIAL, INC. STAFF: https://www.inc.com/encyclopedia/human-resource-management.html

LEARNING POLICY INSTITUTE. (2018). *learningpolicyinstitute*. Retrieved from learningpolicyinstitute.org:https://learningpolicyinstitute.org/sites/default/files/body/Teacher_Shortages_Causes_Impacts_2018_MEMO.pdf

Saron & Swapnalekha. (2012). *Human Resource Management, tex and case.* New dheli: S chand and Company Limited.

*thmeythmey*. (2017). Retrieved from thmeythmey web site: https://thmeythmey.com/?page=detail&id=54369

*WIKIPEDIA*. (2020). Retrieved from Wikipedia, the free encyclopedia: https://en.wikipedia.org/wiki/Human_resource_management

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

## កម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត

## សូមគោរព និងជំរាបសួរលោក/លោកស្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់

ខ្ញុំបាទឈ្មោះ សឿន សុខណាង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ " តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យនានាក្នុងខេត្តកណ្តាល"។ អាស្រ័យហេតុនេះសូមលោក/លោកស្រី មេត្តាជួយផ្តល់ចម្លើយចំពោះសំណួរខាងក្រោមដោយក្តីអនុគ្រោះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក/លោកស្រី ក្នុងការជួយចូលរួមសហការជាមួយខ្ញុំបាទ។ រាល់ចម្លើយដែលលោក/លោកស្រីផ្តល់ឲ្យ គឺជាព័ត៌មានដ៏មានសារៈសំខាន់ខ្លាំងបំផុតសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ យកទៅសិក្សានឹងកែលម្អនូវចំណុចខ្វះខាតរបស់ក្រសួង ដើម្បីឲ្យការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមដែលបង្រៀននៅវិទ្យាល័យក្នុងខេត្តកណ្តាល កាន់តែមានភាពឆ្លើយតបនឹងតម្រូវការ ។ សូមលោក/លោកស្រី មេត្តាផ្តល់នូវចម្លើយពិតប្រាកដ ដើម្បីឲ្យការសិក្សាស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវសន្យានឹងរក្សាក្រមសីលធម៌ក្នុងការស្រាវជ្រាវ រក្សាសិទ្ធ និងកិត្តិយសជូនលោក/លោកស្រី ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់។

**អំពីព័ត៌មានផ្ទាល់ខ្លួន ស្ថិតិវិទ្យាល័យ និងស្ថិតិគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្ត**

១. ភេទ៖ ☐ ប្រុស ☐ ស្រី

២. អាយុ៖ ............ឆ្នាំ តួនាទី៖.............................. លេខទូរស័ព្ទ៖...........................

៣.តើក្នុងខេត្តរបស់លោក/លោកស្រីមានវិទ្យាល័យចំនួនប៉ុន្មាន?

សាលាចំនួន៖

•តំបន់ជនបទចំនួន....... •តំបន់ទីប្រជុំជនចំនួន........

៤. តើក្នុងខេត្តលោក/លោកស្រីមានគ្រូបង្រៀនកម្រិតឧត្តមប៉ុន្មាននាក់? ក្នុងនោះស្រីប៉ុន្មាន?

•ប្រុស........នាក់ •ស្រី..........នាក់

៥.តើក្នុងខេត្តរបស់លោក/លោកស្រីមានវិទ្យាល័យចំនួនប៉ុន្មានដែលខ្វះនិងលើសគ្រូបង្រៀនកម្រិតឧត្តម?

•វិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមមានចំនួនៈ .........................

•វិទ្យាល័យដែលលើសគ្រូបង្រៀនកម្រិតឧត្តមមានចំនួនៈ...........................

៦. តើវិទ្យាល័យក្នុងខេត្តរបស់លោក/លោកស្រីដែលខ្វះគ្រូភាគច្រើននៅជនបទ ឬទីប្រជុំជន?

☐ ជនបទ ☐ ខ.ទីប្រជុំជន

៧.តើវិទ្យាល័យក្នុងខេត្តរបស់លោក/លោកស្រីដែលលើសគ្រូភាគច្រើននៅជនបទ ឬទីប្រជុំជន ?

☐ ជនបទ ☐ ទីប្រជុំជន

៨.តើការបែងចែកគ្រូកម្រិតឧត្តមចេញថ្មីកន្លងមក មន្ទីរបានអនុវត្តន៍យ៉ាងដូចម្តេច ?

☐ ចាត់តាំងទៅវិទ្យាល័យខ្វះគ្រូ ☐ សាមីខ្លួនជ្រើសរើសវិ.ដោយខ្លួនឯង

**អំពីមតិយោបល់**

៩.តើមូលហេតុអ្វីខ្លះដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យនានានៅក្នុងខេត្តរបស់លោក/លោកស្រី?

.....................................................................................................................

.....................................................................................................................

.....................................................................................................................

១០.តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យមានបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យនានានៅក្នុងខេត្តរបស់លោក/លោកស្រី?

.....................................................................................................................

.....................................................................................................................

.....................................................................................................................

១១.តើក្នុងខេត្តរបស់លោក/លោកស្រីជួបបញ្ហាប្រឈមអ្វីខ្លះ ចំពោះបញ្ហាខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១២.តើក្នុងខេត្តរបស់លោក/លោកស្រីជួបបញ្ហាប្រឈមអ្វីខ្លះ ចំពោះបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៣.តើលោក/លោកស្រីមានវិធានការដូចម្តេចខ្លះ ចំពោះបញ្ហាប្រឈមដោយសារខ្វះគ្រូបង្រៀនកម្រិតឧត្តម?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៤.តើលោក/លោកស្រីចាត់វិធានការដូចម្តេចខ្លះ ចំពោះបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តម?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៥.តើលោក/លោកស្រីមានយោបល់និងសំណូមពរដូចម្តេចខ្លះ ចំពោះការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ននេះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក

## កម្រងសំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំការិយាល័យការិយាល័យអប់រំក្រុង ស្រុក

## សូមគោរព និងជំរាបសួរលោក/លោកស្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់

ខ្ញុំបាទឈ្មោះ សឿន សុខណាង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ " តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យនានាក្នុងខេត្តកណ្ដាល"។ អាស្រ័យហេតុនេះសូមលោក/លោកស្រី មេត្តាជួយផ្តល់ចម្លើយចំពោះសំណួរខាងក្រោមដោយក្តីអនុគ្រោះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក/លោកស្រី ក្នុងការជួយចូលរួមសហការជាមួយខ្ញុំបាទ។ រាល់ចម្លើយដែលលោក/លោកស្រីផ្តល់ឲ្យ គឺជាព័ត៌មានដ៏មានសារៈសំខាន់ខ្លាំងបំផុតសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ យកទៅសិក្សានឹងកែលម្អនូវចំណុចខ្វះខាតរបស់ក្រសួងដើម្បីឲ្យការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមដែលបង្រៀននៅវិទ្យាល័យក្នុងខេត្តកណ្តាល កាន់តែមានភាពឆ្លើយតបនឹងតម្រូវការ ។ សូមលោក/លោកស្រី មេត្តាផ្តល់នូវចម្លើយពិតប្រាកដ ដើម្បីឲ្យការសិក្សាស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវសន្យានឹងរក្សាក្រមសីលធម៌ក្នុងការស្រាវជ្រាវ រក្សាសិទ្ធនិងកិត្តិយសជូនលោក/ស្រីលោក ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់។

**អំពីព័ត៌មានផ្ទាល់ខ្លួន និងស្ថិតិវិទ្យាល័យ និងគ្រូបង្រៀនកម្រិតឧត្តមក្នុងស្រុក**

១. ភេទ៖ ☐ប្រុស ☐ស្រី

២. អាយុ៖ ............ឆ្នាំ តួនាទី៖........................................លេខទូរស័ព្ទ៖.................................

៣.ឈ្មោះស្រុក..................................................

៤.តើក្នុងស្រុករបស់លោក/លោកស្រីមានវិទ្យាល័យចំនួនប៉ុន្មាន?

សាលាចំនួន៖

- តំបន់ជនបទចំនួន.......
- តំបន់ទីប្រជុំជនចំនួន........

៥. តើក្នុងស្រុករបស់លោក/លោកស្រីមានគ្រូបង្រៀនកម្រិតឧត្តមប៉ុន្មាននាក់? ក្នុងនោះស្រីប៉ុន្មាន?

•ប្រុស........នាក់ •ស្រី..........នាក់

៦.តើក្នុងស្រុករបស់លោក/លោកស្រី មានវិទ្យាល័យចំនួនប៉ុន្មាន ដែលខ្វះ និងលើសគ្រូបង្រៀនកម្រិតឧត្តម?

•វិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តមមានចំនួនៈ .........................

| ឈ្មោះវិទ្យាល័យដែលខ្វះគ្រូបង្រៀនកម្រិតឧត្តម | ចំនួនគ្រូដែលខ្វះ |
|---|---|
| | |
| | |
| | |
| | |
| | |

•វិទ្យាល័យដែលលើសគ្រូបង្រៀនកម្រិតឧត្តមមានចំនួនៈ...........................

| ឈ្មោះវិទ្យាល័យដែលលើសគ្រូបង្រៀនកម្រិតឧត្តម | ចំនួនគ្រូដែលលើស |
|---|---|
| | |
| | |
| | |
| | |
| | |

៧. តើវិទ្យាល័យក្នុងស្រុករបស់លោក/លោកស្រីដែលខ្វះគ្រូភាគច្រើននៅជនបទ ឬទីប្រជុំជន?

☐ជនបទ ☐ ខ.ទីប្រជុំជន

៨.តើវិទ្យាល័យក្នុងស្រុករបស់លោក/លោកស្រីដែលលើសគ្រូភាគច្រើននៅជនបទ ឬទីប្រជុំជន ?

☐ជនបទ ☐ ទីប្រជុំជន

៩.តើកន្លងមកការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក អនុវត្តវិធានការណាមួយក្នុងការចាត់តាំងបន្តគ្រូឧត្តមចេញថ្មី?

☐ អនុវត្តតាមចំណាត់ការរបស់មន្ទីរ ☐ លើកយោបល់សុំប្តូរសាលា

**អំពីមតិយោបល់**

១០.តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យនានានៅក្នុងស្រុករបស់លោក/លោកស្រី?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

១១.តើមូលហេតុអ្វីខ្លះដែលនាំឱ្យមានបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តម នៅតាមវិទ្យាល័យនានានៅក្នុងស្រុករបស់លោក/លោកស្រី?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

១២.តើក្នុងស្រុករបស់លោក/លោកស្រីជួបបញ្ហាប្រឈមអ្វីខ្លះ ចំពោះបញ្ហាខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

១៣.តើក្នុងស្រុករបស់លោក/លោកស្រីជួបបញ្ហាប្រឈមអ្វីខ្លះ ចំពោះបញ្ហាលើសគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

១៤.តើលោក/លោកស្រីមានវិធានការដូចម្ដេចខ្លះ ចំពោះបញ្ហាប្រឈមដោយសារខ្វះគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

១៥.តើលោក/លោកស្រីចាត់វិធានការដូចម្ដេចខ្លះ ចំពោះបញ្ហាប្រឈមដោយសារលើសគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

១៦.តើលោក/លោកស្រីមានយោបល់និងសំណូមពរដូចម្ដេចខ្លះ ចំពោះការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ននេះ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងវិទ្យាល័យ

## កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងវិទ្យាល័យ

## សូមគោរព និងជំរាបសួរលោក/លោកស្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់

ខ្ញុំបាទឈ្មោះ សឿន សុខណាង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ " តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យនានាក្នុងខេត្តកណ្ដាល"។ អាស្រ័យហេតុនេះ សូមលោក/លោកស្រី មេត្តាជួយផ្ដល់ចម្លើយចំពោះសំណួរខាងក្រោមដោយក្ដីអនុគ្រោះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក/លោកស្រី ក្នុងការជួយចូលរួមសហការជាមួយខ្ញុំបាទ។ រាល់ចម្លើយដែលលោក/លោកស្រីផ្ដល់ឲ្យ គឺជាព័ត៌មានដ៏មានសារៈសំខាន់ខ្លាំងបំផុតសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ យកទៅសិក្សានឹងកែលម្អនូវចំណុចខ្វះខាតរបស់ក្រសួង ដើម្បីឲ្យការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម ដែលបង្រៀននៅវិទ្យាល័យក្នុងខេត្តកណ្ដាលកាន់តែមានភាពឆ្លើយតបនឹងតម្រូវការ ។ សូមលោក/លោកស្រី មេត្តាផ្ដល់នូវចម្លើយពិតប្រាកដ ដើម្បីឲ្យការសិក្សាស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវសន្យានឹងរក្សាក្រមសីលធម៌ក្នុងការស្រាវជ្រាវ រក្សាសិទ្ធ និងកិត្តិយសជូនលោក/លោកស្រី ដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់។

**អំពីព័ត៌មានផ្ទាល់ខ្លួន ស្ថិតិគ្រូបង្រៀនកម្រិតឧត្តមក្នុងវិទ្យាល័យ**

១. ភេទ៖ ☐ប្រុស ☐ស្រី

២. អាយុ៖ ............ឆ្នាំ តួនាទី៖.............................. លេខទូរសព្ទ.......................................

៣.ឈ្មោះវិទ្យាល័យ.................................................... ស្រុក............................................

៤.តើក្នុងសាលារៀនរបស់លោក/លោកស្រីមានគ្រូបង្រៀនកម្រិតឧត្តមចំនួនប៉ុន្មាននាក់? ក្នុងនោះស្រីប៉ុន្មាននាក់?

ក.ប្រុស........នាក់ ខ.ស្រី...........នាក់

⊗កំណត់សម្គាល់៖

- ចំពោះសំណួរទី៥ បើលោក/លោកស្រីឆ្លើយចំណុច "ក" សូមបំពេញក្នុងតារាងដែលខ្វះ បើលោក/លោកស្រីឆ្លើយចំណុច "ខ" សូមបំពេញក្នុងតារាងដែលលើស
- ចំពោះសំណួរទី៧ ទី៨ និងសំណួរទី៩ បើលោក/លោកស្រីឆ្លើយចំណុច "ក" គឺចំណុច "ក" ទាំងអស់ បើឆ្លើយចំណុច "ខ" គឺចំណុច "ខ" ទាំងអស់។

៥. តើក្នុងសាលារៀនលោក/លោកស្រីខ្វះ ឬលើសគ្រូកម្រិតឧត្តមប៉ុន្មាននាក់? មុខវិជ្ជាអ្វីខ្លះ?

ក.ខ្វះ............នាក់ ខ.លើស.............នាក់

| មុខវិជ្ជា | K | I | H | G | M | P | C | B | Es | Ec | E | IT | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ្វះ | | | | | | | | | | | | | |
| លើស | | | | | | | | | | | | | |

**☝ចំណាំ៖ K=ភាសាខ្មែរ, I=សីល-ពលរដ្ឋ, H=ប្រវត្តិវិទ្យា, G=ភូមិវិទ្យា, M=គណិតវិទ្យា, P=រូបវិទ្យា, C=គីមីវិទ្យា, B=ជីវវិទ្យា, Es=ផែនដីវិទ្យា, Ec=សេដ្ឋកិច្ច, E=អង់គ្លេស, IT=ព័ត៌មានវិទ្យា**

៦. តើវិទ្យាល័យរបស់លោក/លោកស្រីស្ថិតនៅក្នុងតំបន់ជនបទ ឬទីប្រជុំជន?

☐ ជនបទ ☐ ទីប្រជុំជន

៧.តើមន្ទីរបានសាកសួរអំពីតម្រូការគ្រូបង្រៀនកម្រិតឧត្តមឬទេ មុននឹងបញ្ជូនគ្រូចេញថ្មីចូល?

☐ មិនដែល ☐ សាកសួរជាមុន

**អំពីមតិយោបល់**

៨.តើមូលហេតុអ្វីខ្លះដែលនាំឱ្យខ្វះ ឬលើសគ្រូបង្រៀនកម្រិតឧត្តមក្នុងវិទ្យាល័យរបស់លោក/លោកស្រី?

ក.មូលហេតុខ្វះគ្រូ៖

..............................................................................................................................

..............................................................................................................................

..............................................................................................................................

ខ.មូលហេតុលើសគ្រូ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៩.តើវិទ្យាល័យរបស់លោក/លោកស្រីជួបបញ្ហាប្រឈមអ្វីខ្លះ ចំពោះការខ្វះ ឬលើសគ្រូបង្រៀនកម្រិតឧត្តម?

ក.បញ្ហាប្រឈមចំពោះការខ្វះគ្រូ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ខ.បញ្ហាប្រឈមចំពោះការលើសគ្រូ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១០.តើលោក/លោកស្រីមានវិធានការដូចម្តេចខ្លះចំពោះបញ្ហាប្រឈមដោយសារខ្វះ ឬលើសគ្រូបង្រៀនកម្រិតឧត្តមក្នុងសាលារៀនរបស់លោក/លោកស្រី?

ក.វិធានការចំពោះបញ្ហាប្រឈមដោយសារខ្វះគ្រូ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ខ.វិធានការចំពោះបញ្ហាប្រឈមដោយសារលើសគ្រូ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១១.តើលោក/លោកស្រីមានយោបល់ និងសំណូមពរដូចម្តេចខ្លះ ចំពោះការផ្តត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តមរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ននេះ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

# ឧបសម្ព័ន្ធទី៤៖ លិខិតបង្គាប់ការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :០៧៤ វជអ.**

## លិខិតបង្គាប់ការ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត សឿន សុខណាង ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

ឯកឧត្តម នៀ សុផន

២-គ្រូដឹកនាំរង

លោកបណ្ឌិត ឈាង សង្វាត

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
**ជ.នាយកវិទ្យាស្ថានជាតិអប់រំ**
**នាយករង**

**បណ្ឌិត.នួន_រីរ៉ា**

**កន្លែងទទួល៖**
- -ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារវិទ្យាស្ថានជាតិអប់រំ
- -ឯកសារវិទ្យាស្ថានជាតិអប់រំ

ឧបសម្ព័ន្ធទី៥៖ លិខិតចុះប្រមូលទិន្នន័យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :**១០៤**.ខជអ.** ន.ក

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល**

**កម្មវត្ថុ៖** សម្រួលដល់ការចុះប្រមូលទិន្នន័យរបស់និស្សិតឈ្មោះ **សឿន សុខណាង** ក្នុងខេត្តកណ្ដាល។
**យោង៖** ផែនការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា លោក **សឿន សុខណាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្ដុះបណ្ដាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្ដីពី « **តម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនកម្រិតឧត្តម**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ លោក **សឿន សុខណាង** នឹងប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE DATA COLLECTION) នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុងស្រុកនិងវិទ្យាល័យនានានៅខេត្តកណ្ដាលដែលប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្ដីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**